**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អំណាចរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ទេព គៅស្រាន់**

កញ្ញា **ឌី ណាសូនាថ**

ណែនាំដោយ

លោក **ឌួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ទេព កៅស្រាន់** និងនាងខ្ញុំឈ្មោះ **ឌី ណាសូនាថ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ ទី២៣ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០២២ និង ២០២៣ ។

ជាកិច្ចចាប់ផ្តើមយើងខ្ញុំសូមគោរពលំឱនកាយវាចាចិត្តសម្តែងនូវគារវកិច្ច និងមហាកតញ្ញូដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះលោកតា **គាំ ឡេង** និងលោកយាយ **ស៊ុន នី** រួមទាំងលោកឪពុក **ទេព ធី** និងអ្នកម្តាយ **គាំ ស្រីមុំ** លោកឪពុក **ឌុន យ៉ានម៉ារឌី** និងអ្នកម្តាយ **ក្រូច ស៊ីណា** ។ កូនសូមអនុញ្ញាតសម្តែងនូវការដឹងគុណចំពោះ គុណូបការៈដ៏ធំធេង បំផុតពុំអាចកាត់ថ្លៃបានរបស់លោកតា លោកយាយ លោកឪពុកអ្នកម្តាយទាំងទ្វេ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ទំនប់បំរុងគ្រប់សព្វបែបយ៉ាងដល់ កូនៗទាំងពីរតាំងពីពេលនៅក្នុងពោះ រហូតដល់កូនបានធំដឹងក្តី ។ រយៈពេល ២០ជាងឆ្នាំកន្លងមកនេះ ដែលកូនបានរស់នៅជាគ្រួសារតែមួយជាមួយលោកឪពុកអ្នកម្តាយ លោកទាំងទ្វេតែងតែ ទូន្មាន ប្រៀនប្រដៅ ផ្តល់ដំបូន្មានល្អៗ លើកទឹកចិត្ត ថ្នាក់ថ្នមថែរក្សាការពារកូនចៅ អស់ពីកម្លាំងកាយចិត្ត ដើម្បីឱ្យកូនក្លាយជាមនុស្សប្រកបដោយកិត្តិគុណ សីលធម៌ គុណធម៌ដ៏ប្រពៃបំផុត។

យើងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណដល់ ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** ជាសាកលវិទ្យាធិការ សាកលវិទ្យាធិការ រង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងលោក លោកស្រី សាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានធ្វើការយកចិត្តទុកដាក់ ក្នុងការអប់រំ ផ្តល់ចំណេះដឹង និងសីលធម៌ដល់យើងខ្ញុំទាំងពីររូបអស់រយៈពេលបួនឆ្នាំកន្លងមកនេះ ក៏ដូចជាជួយសម្របសម្រួលក្នុងការស្រាវជ្រាវ ឯកសារនានា។

ជាពិសេស យើងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណដល់ លោក **ជួន ប៊ុនធី** ដែលជាគ្រូណែនាំបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំពន្យល់ ពិនិត្យ អប់រំ និងកែតម្រូវនូវចំណុចខ្វះខាត នៃសារណានេះតាំងពីពេលចាប់ផ្តើមសរសេរសារណាបញ្ចប់ការសិក្សានេះ រហូតដល់ពួកយើងទទួលបានលទ្ធផលស្អាតរ។

ជាចុងក្រោយ យើងខ្ញុំទាំងពីររូបសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ និងបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកយើងនេះ មេត្តាតាមថែរក្សាដល់អ្នកមានគុណទាំងបួន លោកតា លោកយាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងលោក លោកស្រីសាស្ត្រាចារ្យ រួមទាំងសិស្សច្បង ព្រមទាំងសូមទទួលបាននូវពុទ្ធពរទាំងបួន ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមខ្ញុំបាទ **ទេព កៅស្រាន់** និងនាងខ្ញុំ **ឌី ណាសូនាថ** សូមធ្វើការស្វាគមន៍ចំពោះសិស្សប្អូនជាពិសេសសិស្សនិស្សិតជាទីរាប់អាន និងសាស្ត្រាចារ្យជាទីគោរព ។ ក្រោយពីបានឆ្លងកាត់ការសិក្សានិងក្រេបជញ្ជក់ចំណេះដឹងចាប់តាំងពីឆ្នាំទីមួយរហូតដល់បញ្ចប់ការសិក្សានៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ពួកយើងពិតជាមានកិត្តិយស ដែលសាកលវិទ្យាល័យបានផ្តល់នូវឱកាសដល់រូបយើងខ្ញុំក្នុងការតាក់តែងសារណាច្បាប់សិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ ។ ក្នុងរយៈពេល៤ឆ្នាំនេះ យើងខ្ញុំបានសិក្សានូវមុខជ្ជាយ៉ាងច្រើន ប៉ុន្តែក្នុងមុខវិជ្ជាមួយដែលក្នុងមុខវិជ្ជាផ្សេងទៀតយើងខ្ញុំបានសម្រេចចិត្តតាក់តែងសារណានោះគឺ មុខវិជ្ជានីតិនីតិវិធីព្រហ្មទណ្ឌ ។ ដូចនេះយើងខ្ញុំសម្រេចចិត្តជ្រើសរើសសរសេរសារណាក្រោមប្រធានបទ ស្តីអំពី "**អំណាចរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ**" ។ ការជ្រើសរើសនេះយើងបានឆ្លងកាត់នូវការពិភាក្សា ពិគ្រោះ និងផ្តល់យោបល់ពីសំណាក់លោកសាស្ត្រាចារ្យយ៉ាងហ្មត់ចត់ និងយល់ឃើញថា "**អំណាចរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ**" ពិតជាប្រយោជន៍ និងសារៈសំខាន់ណាស់ក្នុងការអនុវត្តនៅក្នុងនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌសុទ្ធសឹងពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរផ្សេងៗ។

យើងខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំងណាស់ ដែលបានតាក់តែងសារណារនេះឡើងក្រោមប្រធានស្តីពី "**អំណាចរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ**" ដែលមានលោក **ជួន ប៊ុនធី** ដែលជាជំនួយខាងផ្នែកចំណេះដឹងដល់រូបយើងខ្ញុំទាំងពីរក្នុងការតាក់តែងសារណារយ៉ាងរលូន និងបានផ្តល់យោបល់ណែនាំរួមទាំងបានផ្តល់ឯកសារពាក់ព័ន្ធដល់រូបយើងខ្ញុំទាំងពីរ ។ យើងខ្ញុំទាំងពីរនាក់សង្ឃឹម និងជឿជាក់យ៉ាងមុតមាំថាសារណាមួយនេះ នឹងក្លាយជាឯកសារចម្បងដែលមានសារៈសំខាន់មួយក្នុងការស្រាវជ្រាវដល់ និស្សិតជំនាន់ក្រោយៗដើម្បីជាជំនួររកស្មារតី និងចំណេះដឹង។

ទោះជាបីជាមានការខិតខំស្រាវជ្រាវការត្រួតពិនិត្យ និងការកែតម្រូវយ៉ាងណាក៏សារណានេះនៅតែមានចំណុចដែលខ្វះខាតទៅលើខ្លឹមសារ និងផ្នែកកំហុសខុសឆ្គងផ្នែកអក្ខរាវិរុទ្ធ ។ ដូច្នេះយើងខ្ញុំទាំងពីររូបសូមធ្វើការអធ្យាស្រ័យ និងសូមអភ័យទោសចំពោះកំហុសខុសឆ្គងទាំងឡាយពីសំណាក់ លោក លោកស្រី សាស្ត្រានិងសិស្សនិស្សិតគ្រប់មជ្ឈដ្ឋាន។ យើងខ្ញុំទាំងពីររូបរងចាំការរិះ គន់ និងកែតម្រូវ ក្នុងន័យស្ថាបនា ដើម្បីឱ្យសមិទ្ធិផលមួយនេះ កាន់តែប្រសើរឡើង និងសូមគោរពអរគុណចំពោះ ការរិះគន់។

ជាទីបញ្ចប់នេះ សូមជូនពរដល់ អស់លោក លោកស្រី សាស្ត្រាចារ្យ និងសិស្ស និស្សិត មិត្តអ្នកអានគ្រប់រូបឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ និងរកស៊ីទទួលទានមានបានដូចសេចក្តីប្រាថ្នា។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម** ............ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ**

**១.១.លក្ខណៈសម្បត្តិដែលអាចក្លាយជាចៅក្រមស៊ើបសួរ** ............ ៤

១.១.១.លក្ខន្តិកៈនៃចៅក្រមស៊ើបសួរ ............ ៤

១.១.២.ការដកហូតចៅក្រមស៊ើបសួរ ............ ៥

**១.២.សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ** ............ ៥

១.២.១.សមត្ថកិច្ចតាមសាច់រឿង ............ ៥

១.២.២.សមត្ថកិច្ចដែនដី ............ ៦

**១.៣.ការចាប់ផ្ដើមបើកការស៊ើបសួរ** ............ ៦

១.៣.១.ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ............ ៧

១.៣.២.បណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ............ ៨

១.៣.២.១.ការបញ្ជូនពាក្យបណ្ដឹងទៅព្រះរាជអាជ្ញា ............ ៨

១.៣.២.២.ការបង់ប្រាក់តម្កល់ ............ ៩

១.៣.២.៣.បណ្ដឹងដោយបំពាន ឬបណ្ដឹងដោយអូសបន្លាយពេលវេលា ............ ៩

១.៣.៣.វិសាលភាពនៃបណ្ដឹង ............ ១០

**១.៤.ការស្នើសុំបំពេញកិច្ចស៊ើបសួរ** ............ ១១

១.៤.១.ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា ............ ១១

១.៤.២.ការស្នើសុំបំពេញកិច្ចដោយជនត្រូវចោទ ............ ១១

១.៤.៣.ការស្នើសុំបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី ............ ១២

**ជំពូកទី២**

**កិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

**២.១.វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ............ ១៣

២.១.១.ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ ............ ១៣

២.១.២.ការសួរចម្លើយជនត្រូវចោទ....................................................................................................១៤
២.១.៣.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ...........................................................................................១៥
២.១.៤.ការស្តាប់ចម្លើយសាក្សី .........................................................................................................................១៦
២.១.៥.ការឆែកឆេរ និងការចាប់យកវត្ថុតាង ...................................................................................................១៦
២.១.៦.កោសលវិច័យ.........................................................................................................................................១៧
២.១.៦.១.ភាពចាំបាច់នៃការធ្វើកោសលវិច័យ .....................................................................................១៧
២.១.៦.២.បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ..................................................................................................១៨
២.១.៦.៣.របាយការណ៍ និងសោហ៊ុយសម្រាប់ធ្វើកោសលវិច័យ .........................................................១៩
២.១.៧.ការស្តាប់ទូរស័ព្ទ .....................................................................................................................................២០
២.១.៨.ដីកាចាត់ឱ្យស៊ើបសួរជំនួស ....................................................................................................................២១
**២.២.វិធានការនិរន្តរាយ**.......................................................................................................................................២២
២.២.១.ដីកាបង្គាប់ឱ្យចូលខ្លួន............................................................................................................................២២
២.២.១.១.អត្ថន័យ ...........................................................................................................................................២២
២.២.១.២.និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចូលខ្លួន.....................................................................២៣
២.២.២.ដីកាបង្គាប់ឱ្យនាំខ្លួន..............................................................................................................................២៣
២.២.២.១.អត្ថន័យ...........................................................................................................................................២៣
២.២.២.២.និទ្ទេសដែលចៅក្រមស៊ើបសួរត្រូវចុះលើដីកាបង្គាប់ឱ្យនាំខ្លួន...............................................២៤
២.២.២.៣.ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ............................................................................................២៤
២.២.៣.ដីកាបង្គាប់ឱ្យចាប់ខ្លួន ...........................................................................................................................២៥
២.២.៣.១.អត្ថន័យ...........................................................................................................................................២៥
២.២.៣.២.លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន .........................................................................២៥
២.២.៣.៣.និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចាប់ខ្លួន.......................................................................២៥
២.២.៣.៤.ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន និងការបង្ហាញខ្លួនរបស់ជនពាក់ព័ន្ធ ...................២៦
២.២.៤.ការឃុំខ្លួនបណ្តោះអាសន្ន.........................................................................................................................២៧
២.២.៤.១.ការសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន.............................................................................២៧
២.២.៤.២.លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ................................................................................២៩

២.២.៤.៣.មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ..........................................................២៩
២.២.៤.៤.ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន..........................................................២៩
២.២.៤.៥.ការប្រតិបត្តិនៃការឃុំខ្លួនបណ្ដោះអាសន្ន..........................................................៣៤
២.២.៥.ការដាក់ជនត្រូវចោទស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ..........................................៣៥
២.២.៥.១.ប្រភេទនៃដីកាសម្រេចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ...៣៥
២.២.៥.២.ដីកាសម្រេចដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ .......................................៣៦

## ជំពូកទី៣

## ការបិទការស៊ើបសួរ

**៣.១.នីតិវិធីនៃការបិទការស៊ើបសួរ** ..........................................................៣៩
៣.១.១.ការជូនដំណឹង ..........................................................៣៩
៣.១.២.ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ..........................................................៣៩
**៣.២.ដីកាដំណោះស្រាយ** ..........................................................៤០
៣.២.១.ដីកាបញ្ជូនរឿងទៅជំនុំជម្រះ..........................................................៤០
៣..២.២.ដីកាលើកលែងការចោទប្រកាន់..........................................................៤០
**៣.៣.អានុភាពនៃដីកាដំណោះស្រាយ**..........................................................៤២
៣.៣.១.អានុភាពចំពោះការឃុំខ្លួនបណ្ដោះអាសន្ន ..........................................................៤២
៣.៣.២.អានុភាពចំពោះការត្រួតពិនិត្យតាមផ្លូវតុលាការ ..........................................................៤៣
**សេចក្ដីសន្និដ្ឋាន** ..........................................................៤៤
**អនុសាសន៍** ..........................................................៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងឆ្នាំ ១៩៩៣ កម្ពុជាបានបង្កើតឱ្យរស់រាននូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ តាមរយៈច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ។ អង្គការសហប្រជាជាតិ បានបង្កើតឱ្យមានអាជ្ញាធរជាបណ្តោះអាសន្នដែលមាន ឈ្មោះហៅថា "**អ៊ុនតាក់**" ដែលមានភារកិច្ចក្នុងការត្រួតពិនិត្យផ្ទាល់លើលើគ្រប់វិស័យទាំងឡាយ ស្តីពី ការរក្សារបៀបរាបរយសង្គម ការគោរពច្បាប់ ការការពារសិទ្ធិមនុស្ស ការអនុវត្តច្បាប់ និងដំណើរការ ក្នុងប្រព័ន្ធតុលាការ ។ ដោយមានកង្វល់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធច្បាប់ និងប្រព័ន្ធតុលាការ និងសេចក្តីត្រូវការជាចាំបាច់ នាគ្រានោះ អ៊ុនតាក់ បានបង្កើតឱ្យមាននូវច្បាប់ដើម្បីអនុវត្តក្នុងគ្រាបណ្តោះអាសន្ន ហើយបង្កើតបានជា បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់ការអនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ឬ ហៅកាត់ថា ច្បាប់ព្រហ្មទណ្ឌអន្តរកាល ការបង្កើតនៅបញ្ញត្តិច្បាប់នេះ គឺ សង្ឃឹមថានឹងដាក់អនុវត្តក្នុងអំឡុងពេលខ្លី ដែលកម្ពុជាពុំទាន់បានចងក្រម ឬ បង្កើតនូវប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនៅឡើយតែប៉ុណ្ណោះ ប៉ុន្តែពេលកម្ពុជាបានរៀបចំនូវការបោះឆ្នោតរបស់ខ្លួនជាលើកដំបូងក្នុងឆ្នាំ ១៩៩៣ រួចមក ដោយសារខ្វះពិសោធន៍ និងអ្នកជំនាញការផ្លូវច្បាប់ និងធនធានផងនោះ កម្ពុជាក៏នៅតែបន្តអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះរហូតដល់ឆ្នាំ ២០០៧ ទើបព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះនរោត្តសីហមុនី បានចេញព្រះរាជក្រឹត្យលេខៈ នស/ រកម/០៨០៧/០២៤ ចុះ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើនូវក្រមនីតិវិធីព្រហ្មទណ្ឌដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលពី ២ ។

នីតិវិធីព្រហ្មទណ្ឌសំដៅដោយផ្ទាល់ដល់រឿងក្តីព្រហ្មទណ្ឌ ពោលគឺរបៀបរៀបចំដំណើរនៃការ ប្រព្រឹត្ត ឬប្រតិបត្តិរបស់សង្គមមនុស្សតបទៅនឹងអំពើ ភាពរឹករវ សកម្មភាពដែលច្បាប់បញ្ញត្តិថាជាបទល្មើស ។ នីតិវិធីព្រហ្មទណ្ឌ និងធ្វើការបង្ហាញដោយអ្នកសិក្សាឱ្យយល់ដឹងពីការប្រព្រឹត្តទៅនៃនីតិវិធី និងវិធានទាំងឡាយដែលប្រព្រឹត្តដោយភាគីដែលចូលរួមក្នុងដំណើរនៃកិច្ចរបស់តុលាការក្នុងបទល្មើសព្រហ្មទណ្ឌនីមួយៗ។

ជាការពិតណាស់ច្បាប់ព្រហ្មទណ្ឌអន្តរកាល គឺមាន ៧៥ មាត្រា ចំណែកឯក្រមនីតិវិធីព្រហ្មទណ្ឌមានបញ្ញត្តិមាត្រារហូតដល់ ៦១២ មាត្រា ។ នីតិវិធីព្រហ្មទណ្ឌ វាមិនមែនគ្រាន់តែជាផ្នែកមួយនៃដំណើរការនីតិវិធីរបស់តុលាការ ឬ សាលាជំនុំជម្រះក្តីតែមុខនោះទេ ប៉ុន្តែវាជាបណ្តុំនៃវិធានដែលកំណត់នូវ សិទ្ធិ កាតព្វកិច្ចរបស់បុគ្គលិក ឬ ភាគីដែលបានចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងដំណើរការរបស់សាលាជំនុំជម្រះក្តី និង

សកម្មភាព របស់តុលាការព្រហ្មទណ្ឌ ចាប់តាំងពីពេលដែលមានការសង្ស័យថាមានបទល្មើសកើតឡើងរហូតដល់ ពេលដែលចារី សហចារី អ្នកសមគំនិត អ្នកផ្តើមគំនិត នៃការប្រព្រឹត្តបទល្មើសដែលត្រូវបានកំណត់អត្តសញ្ញាណ និងផ្តន្ទាទោសនោះចាប់ផ្តើមអនុវត្តទោសរបស់ពួកគេ ។

នីតិវិធីព្រហ្មទណ្ឌនឹងធានាដល់ការអនុវត្តយ៉ាងពិតប្រាកដនូវនីតិព្រហ្មទណ្ឌនីតិវិធីមានសារៈ សំខាន់ក្នុងនីតិព្រហ្មទណ្ឌ ដែលអាចឱ្យគេស្វែងរកនូវ អត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ ក្នុងល័ក្ខខណ្ឌឃ្លាំមើលផលប្រយោជន៍របស់សង្គម ដោយឆ្លើយតបទៅនឹងព្យសនកម្មរបស់សមូហភាព និងជនរងគ្រោះ និងបង្រ្កាបយ៉ាងឆាប់រហ័ស និងពិតប្រាកដនូវរាល់បទល្មើសព្រហ្មទណ្ឌ ដើម្បីធានាដល់ការផ្តន្ទាទោស យ៉ាងសមរម្យមួយរាល់ប្រធាននៃបទល្មើស ។ ភាពប្រសើរនៃនីតិវិធីព្រហ្មទណ្ឌ និងធានាស្វែងរកនូវ យុត្តិធម៌ដល់បណ្តាលអ្នកចូលរួមប្រព្រឹត្តបទល្មើស និងអ្នកទទួលរង់នូវព្យសនកម្មនៃអំពើល្មើស ។ លើសពីនេះទៅទៀតក្រមនីតិវិធីព្រហ្មទណ្ឌគឺមានបួនដំណាក់កាលធំៗ រួមមាន ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ។

## ២.ចំណោទបញ្ហា

បញ្ហាចោទដែលយើងខ្ញុំនឹងលើកឡើងនៅក្នុងប្រធានបទនេះ តើអំណាចនៅក្នុងការស៊ើបសួរចំពោះបទល្មើសព្រហ្មទរបស់ចៅក្រមស៊ើបសួរនឹងមានដំណើរការយ៉ាងដូចម្តេចដើម្បីស្វែងរកការពិត ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទ «**អំណាចរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ**» មានគោលបំណងស្រាយបំភ្លឺនូវចំណោទគតិយុត្តដែលលើកឡើងពាក់ព័ន្ធនឹងការបើកការស៊ើបសួរ រួមទាំងពាក់ព័ន្ធនិងការប្រើប្រាស់នូវវិធានស្រាវជ្រាវ និងវិធានបង្ខំដើម្បីធ្វើឱ្យនីតិវិធីស៊ើបសួរនោះមានដំណើរការល្អប្រសើរ ។ ពោលគឺបកស្រាយឱ្យអ្នកអានបានស្វែងយល់ពីដំណើរការនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរក្នុងការស្វែងរកការពិតជូនដើមបណ្តឹងរដ្ឋប្បវេ-ណី ជនត្រូវចោទ ឬអ្នកដែលពាក់ព័ន្ធ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានការពារដោយយុត្តិធម៌ នៅពេលគាត់ត្រូវបានបំពានសិទ្ធិដោយជនត្រូវចោទ ក៏ដូចជាការពារផលប្រយោជន៍របស់សង្គមជាតិប្រកបដោយចីរភាព និងស្ថេរភាព។

## ៤.ដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះគឺមានវិសាលភាពគ្របដណ្តប់លើ បទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជាអនុវត្តទៅលើជនគ្រប់រូបដែលច្បាប់បានកំណត់ទុកជាមុន ដែលបានប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃការទប់ស្កាត់បទល្មើសណាមួយបានប្រព្រឹត្តអំពើដែលថែងផ្ទុយពីច្បាប់ ។ ជាពិសេសប្រធានបទ «**អំណាចរបស់ចៅក្រមស៊ើបសួរក្នុង**

**រឿងក្តីព្រហ្មទណ្ឌ**» នេះនឹងលើកយករដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ច្បាប់ស្តីពីយុត្តិធម៌សម្រាប់អនីតិជន ឆ្នាំ២០១៦ និងឯកសារនានា ដែលពាក់ព័ន្ធដែលមានអានុភាពគតិយុត្តមកគ្របដណ្តប់លើប្រធានបទនេះ ។ ក៏ប៉ុន្តែយើងខ្ញុំនឹងធ្វើការផ្តោតសំខាន់បំផុតទៅលើច្បាប់ស្តីពី **ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧** ដើម្បីលើកឡើងពីសញ្ញាណខ្លះៗនៃការចៅក្រមស៊ើបសួរ សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ រួមទាំងនីតិវិធីនៃការបិទការស៊ើបសួរនៅក្នុងបទល្មើសព្រហ្មទណ្ឌ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទនេះគឺមានសារៈសំខាន់ ដល់និស្សិតដែលស្រឡាញ់ចូលចិត្តការអានដើម្បីជាទីប្រយោជន៍ក្នុងការធ្វើជាពុទ្ធិរបស់ខ្លួននៅក្នុងវិស័យច្បាប់កម្ពុជា នឹងអាចយកចំណេះដឹងទាំងនេះក្នុងការប្រឡងប្រជែងនានា។ ដោយប្រធានបទនេះយើងខ្ញុំនឹងលើកយកនូវខ្លឹមសារ និងយោងនូវឯកសារដែលពាក់ព័ន្ធដោយច្បាស់លាស់ ហើយបញ្ចេញនូវគំនិតផ្ទាល់ខ្លួនខ្លះក្នុងបកស្រាយនូវខ្លឹមសារមួយចំនួនដើម្បីធ្វើការបង្ហាញនូវរូបភាព រួមទាំងមានជាឧទាហរណ៍ជាក់ស្តែងដែលបានកើតឡើងនៅក្នុងសង្គមជាក់ស្តែង ។ លើសពីនេះទៅទៀតចំពោះនិស្សិតដែលស្រឡាញ់ចូលចិត្តការអាន ។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាកិច្ចបន្តក្នុងការសរសេរបកស្រាយឱ្យកាន់តែស៊ីជម្រៅលើប្រធានបទនេះ យើងខ្ញុំបានធ្វើការបែងចែកនូវរចនាសម្ព័ន្ធនៃការស្រាវជ្រាវដើម្បីសិក្សាជា ០៣ ជំពូកធំៗ៖

**ជំពូកទី១ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ**

**ជំពូកទី២ កិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

**ជំពូកទី៣ ការបិទការស៊ើបសួរ**

# ជំពូកទី១

# សញ្ញាណទូទៅនៃ

# ចៅក្រមស៊ើបសួរ

# ជំពូកទី១

# សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ

ជាធម្មតានៅពេលដែលលេចឡើងនូវបទល្មើសព្រហ្មទណ្ឌមួយកើតឡើង នោះស្ថាប័នរដ្ឋនឹងធ្វើការដាក់ទណ្ឌកម្មទៅលើបុគ្គលទាំងឡាយដែលបានប្រព្រឹត្តបទល្មើស ។ ក៏ប៉ុន្តែមុននឹងឈានដល់ការដាក់ទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះគឺត្រូវរកឱ្យឃើញនូវពិរុទ្ធភាពលើបុគ្គលនោះជាមុនសិន ។ មានន័យថាត្រូវមានការស៊ើបអង្កេត ចោទប្រកាន់ ស៊ើបសួរ និងជំនុំជម្រះជាមុនសិនទើបអាចអនុវត្តទោសលើបុគ្គលនោះបាន ។ ក្នុងជំពូកទី១នេះ នឹងបកស្រាយទៅលើសញ្ញាណទូទៅនៃចៅក្រមស៊ើបសួររួមមាន លក្ខណៈសម្បត្តិដែលអាចក្លាយជាចៅក្រមស៊ើបសួរ(១.១.) សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ(១.២.) ការចាប់ផ្តើមបើកការស៊ើបសួរ(១.៣.) និងការស្នើសុំបំពេញកិច្ចស៊ើបសួរ(១.៤.) ។

## ១.១.លក្ខណៈសម្បត្តិដែលអាចក្លាយជាចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរជាចៅក្រមអសនៈ ដែលទទួលបន្ទុកក្នុងការស៊ើបសួរលើរឿងក្តីព្រហ្មទណ្ឌដើម្បីស្វែករកនូវអត្ថិភាព ឬនត្ថិភាពនៃបទល្មើស។ ដោយលក្ខណៈសម្បត្តិដែលអាចក្លាយជាចៅក្រមស៊ើបសួររួមមាន លក្ខន្តិកៈនៃចៅក្រមស៊ើបសួរ(១.១.១.) និងការចាត់តាំងចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបសួរដោយប្រធានតុលាការលើកលែងតែមានការដកហូតចៅក្រមស៊ើបសួរ(១.១.២.) តាមរយៈបុគ្គលដែលមានសិទ្ធិស្នើសុំឱ្យដកហូត។

### ១.១.១.លក្ខន្តិកៈនៃចៅក្រមស៊ើបសួរ

ដើម្បីអាចក្លាយទៅជាចៅក្រមស៊ើបសួរបាន លុះត្រាតែឆ្លងកាត់ការប្រឡងប្រជែងជ្រើសរើសឱ្យចូលរៀនជាមុនសិនទើបក្លាយទៅជាចៅក្រម ឬព្រះរាជអាជ្ញាបាន ។ ហើយលក្ខណៈសម្បត្តិដែលអាចក្លាយជាចៅក្រមស៊ើបសួរទៀតសោតគឺ តម្រូវឱ្យមានចំណេះដឹងដ៏រឹងមាំក្នុងការស្វែងរកយុត្តិធម៌ជូនបុគ្គលដែលពាក់ព័ន្ធក្នុងបទល្មើសព្រហ្មទណ្ឌ ។ ដោយលក្ខខណ្ឌនៃការប្រឡងប្រជែងជ្រើសរើសឱ្យចូលរៀនមានដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិខ្មែរពីកំណើត
- មានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំ យ៉ាងច្រើនចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ (សែសិប) ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡងត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ
- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន[1]។

**១.១.២.ការដកហូតចៅក្រមស៊ើបសួរ**

ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ដើម្បីប្រគល់ជូនចៅក្រមស៊ើបសួរម្នាក់ទៀត អាចស្នើទៅប្រធានតុលាការ ដើម្បីជាប្រយោជន៍នៃរដ្ឋបាលដ៏ល្អនៃយុត្តិធម៌ ។

ការស្នើសុំនេះអាចធ្វើឡើងដោយពាក្យសុំដែលមាន សំអាងហេតុរបស់ព្រះរាជអាជ្ញាដែលធ្វើឡើងដោយការផ្ដើមគំនិតផ្ទាល់ខ្លួន ឬ តាមរយៈពាក្យប្ដឹងរបស់ភាគី [2]។

មូលហេតុនៃការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួររួមមាន៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រម ជាភាគីណាមួយក្នុងរឿងក្ដី
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី ៦ ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្ដីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការ ជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្ដី
- កាលណាចៅក្រមជា ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្ដី ឬ
- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្ដីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្ដី ឬបានចូលរួមក្នុងការសម្រេចសេចក្ដីនៅសាលាដំបូងដែលបានប្ដឹងឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្ដី[3] ។

## ១.២.សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការស៊ើបសួរតាមរយៈស្ថានភាពចំនួនពីរ គឺសមត្ថកិច្ចតាមសាច់រឿង (១.២.១.) និងសមត្ថកិច្ចតាមដែនដី (១.២.២.)៖

**១.២.១.សមត្ថកិច្ចតាមសាច់រឿង**

តាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានទទួលស្គាល់ថាតុលាការទាំងឡាយអាចប្ដឹងមកខ្លួនឯងដោយខ្លួនឯងផ្ទាល់ដើម្បីបើកការស៊ើបសួរ ឬវិនិច្ឆ័យលើបទល្មើសព្រហ្មទណ្ឌណាមួយឡើយ បើទោះបីតុលាការនោះ

[1] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ,មាត្រា១៩

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៥៣ កថាខណ្ឌទី១

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៥៣ កថាខណ្ឌចុងក្រោយ និងមាត្រា ៥៥៦

បានដឹងដោយផ្ទាល់នូវបទល្មើសក៏ដោយ ។ ដូចនេះចៅក្រមស៊ើបសួរអាចស៊ើបសួរបាន លុះត្រាតែបានដឹងពីរឿងមួយដោយព្រះរាជអាជ្ញាតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដោយការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំពោះមុខចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ។ ឧទាហរណ៍ៈ មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌបានចែងថា បទហិង្សាដោយចេតនា គឺជាអំពើហិង្សាប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ឆ្នាំ ទៅ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។ ផ្អែកតាមឧទាហរណ៍ខាងលើនេះ ព្រះរាជអាជ្ញាមានជម្រើសពីរក្នុងការចោទប្រកាន់ ទី ១ គឺធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បើតំណាងអយ្យការយល់ឃើញថាបទល្មើស មិនជាក់ស្ដែង ឬ មិនមានភស្តុតាងគ្រប់គ្រាន់មិនទាន់អាចកំណត់បាននូវអត្តសញ្ញាណរបស់ចារី សហចារី ។ ជម្រើសនៃការចោទប្រកាន់ទី ២ បើសិនបទល្មើសខាងនេះមានភស្តុតាង សាក្សី និងជនល្មើសត្រូវបានកំណត់អត្តសញ្ញាណ សមល្មមអាចជំនុំជម្រះបាននោះ ព្រះរាជអាជ្ញា អាចធ្វើការចោទប្រកាន់តាមរយៈ ដីកាកោះបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅចៅក្រមជំនុំជម្រះ[4] ។

### ១.២.២.សមត្ថកិច្ចតាមដែនដី

ចៅក្រមដែលមានសមត្ថកិច្ចគឺ :

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស ។ ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្ដឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច ។ វិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល ។ ការសម្រេចនេះបិទផ្លូវតវ៉ា [5]។ មានន័យថា ចៅក្រមស៊ើបសួរមានសមត្ថកិច្ចស៊ើបសួរបានគឺ នៅក្នុងករណីដែលបទល្មើសនោះបានកើតឡើងនៅក្នុងដែនដីរបស់ខ្លួននៃសមត្ថកិច្ចរបស់ខ្លួនដែលខ្លួនបានស្ថិតនៅតែប៉ុណ្ណោះ ។

## ១.៣.ការចាប់ផ្ដើមបើកការស៊ើបសួរ

ផ្អែកតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌមុននឹងចៅក្រមស៊ើបសួរអាចធ្វើការប្រើប្រាស់នូវអំណាចបង្ខំ ឬវិធានការនិរន្តរាយដើម្បីអាចសម្រួលនៅក្នុងកិច្ចស៊ើបសួរបានលុះត្រាតែចៅក្រមស៊ើបសួរមាន ការប្ដឹងរបស់ព្រះ

[4] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌរៀបរៀងដោយ លោកស្រី **ឌី លីឡា** និងលោក **ខាន់ សុខា**, ទំព័រ៦១

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១២៣

រាជអាជ្ញាគឺមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (**១.៣.១.**) ឬមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (**១.៣.២.**) ។

### ១.៣.១.ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ការស៊ើបសួរត្រូវធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ ។ ពោលគឺពុំអាចខកខានបានទេក្នុងការមិនបើកការស៊ើបសួរលើបទឧក្រិដ្ឋ បើពុំដូច្នេះទេត្រូវចាត់ទុកជាមោឃៈ ។

ដោយឡែកចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បានមិនធ្វើការបាន[6] ។ បានន័យថាការស៊ើបសួរចំពោះករណីបទឧក្រិដ្ឋគឺដាច់ខាតត្រូវតែមានការស៊ើបសួរដែលធ្វើឡើងដោយចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដោយឡែកចំពោះបទមជ្ឈិមវិញគឺអាចបើកក៏បាន ឬមិនបើកការស៊ើបសួរក៏បាន ។

ការស៊ើបសួរត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមានៈ

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។ ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរពបើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ[7] ។ ការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។

ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និ-ដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន ។ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ។

កាលបើចៅក្រមស៊ើបសួរទទួលពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញា និងបង្គាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបង់ប្រាក់តម្កល់ទុក ។ កាលណាទទួលពាក្យប្តឹងសាមញ្ញ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យប្តឹងនោះទៅព្រះរាជអាជ្ញា ។ បានសេចក្តីថា

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១២២

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៤ កថាខណ្ឌទី១

នៅពេលដែលមានការដាក់ពាក្យបណ្តឹងធម្មតាដោយពុំមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ ចៅក្រមស៊ើបត្រូវបញ្ជូនពាក្យបណ្តឹងដែលពុំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅព្រះរាជអាជ្ញា[8] ។

**១.៣.២.បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌប្រសិនបើព្រះរាជអាជ្ញា បានតម្កល់រឿងទុកឥតចាត់ការដោយសារតែមូលហេតុនៃការរលត់បណ្តឹងអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការតាំងខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរបានក្នុងការស្វែងរកយុត្តិធម៌ជូនខ្លួន ។ ហើយមូលហេតុនៃការរលត់បណ្តឹងអាជ្ញារួមមាន មរណភាពនៃជនល្មើស ការផុតរលត់អាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ [9] ។ លើសពីនេះទៀតនៅមានមូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញាដែលត្រូវបានចែងដោយច្បាប់ដោយឡែកជាក់លាក់មាន ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យបណ្តឹង នៅក្នុងករណីដែលពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ និងការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល[10] ។ បានសេចក្តីថាប្រសិនព្រះរាជអាជ្ញាបានធ្វើការតម្កល់រឿងទុកឥតចាត់ការដែលជាហេតុធ្វើឱ្យ យុត្តាធិការជំនុំជម្រះពុំមានសមត្ថកិច្ចក្នុងការជំនុំជម្រះទេ នោះដើមបណ្តឹងរដ្ឋប្បវេណីក៏មិនអាចទទួលបានសំណងដែលបង្កដោយបទល្មើសដែរ ។ ពោលគឺដើម្បីទទួលបាននូវសំណងរដ្ឋប្បវេណីត្រូវសម្រេចថាមានពិរុទ្ធភាពជាមុនសិន ទើបដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលបានសំណងដើម្បីជួសជុលព្យនកម្មបាននោះ [11] ។

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរមាន សមត្ថកិច្ចដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ពាក្យប្តឹងអាចដាក់ក្នុងនាមជនរងគ្រោះដោយមេធាវី[12] ។

**១.៣.២.១.ការបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញា**

ចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា ចៅក្រមស៊ើបសួរបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា ។ ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា ត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ ។ ព្រះរាជអាជ្ញាអាចសុំ

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១២៤

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៧

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៨

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៣

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៣៨

ដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបាន ផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា[13] ។ បានសេចក្តីថា ចៅក្រមស៊ើបសួរត្រូវសម្រេចដោយឆន្ទានុសិទ្ធិ គឺចៅក្រមស៊ើបសួរអាចសម្រេចដោយឯករាជ្យពុំមានការជាប់ជុំពាក់និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលស្នើសុំកុំឱ្យស៊ើបសួរលើរឿងនោះឡើយ។

**១.៣.២.២.ការបង់ប្រាក់តម្កល់**

នៅពេលដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើការបង់ប្រាក់តម្កល់។ ដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេច នូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់នេះបានដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ក្នុងករណីដែលមានការបង់ប្រាក់តម្កល់ទុក ដើមបណ្តឹងរដ្ឋប្បវេណីទទួលបង្កាន់ដៃដែល មានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញានិងក្រឡាបញ្ជី ។ ប្រសិនបើប្រាក់តម្កល់ទុកមិនត្រូវបានបង់នៅក្នុងរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ ។ ចៅក្រមស៊ើបសួរនេះសម្រេចតាមដីកាដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ប្រាក់តម្កល់ទុកត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់នីតិវិធីលើកលែងតែបណ្តឹងដោយបំពាន ឬបណ្តឹងដោយអូសបន្លាយពេលវេលា ។

ប្រាក់តម្កល់ទុកត្រូវតម្កល់ទុកនៅក្នុងគណនីពិសេស ដែលបើកនៅក្នុងធនាគារ ឬរក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខយ៉ាងរឹងមាំ ។ ទីកន្លែងនេះត្រូវបានជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធានតុលាការ និងព្រះរាជអាជ្ញា[14] ។

**១.៣.២.៣.បណ្តឹងដោយបំពាន ឬបណ្តឹងដោយអូសបន្លាយពេលវេលា**

ប្រសិនបើការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៣៩

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៤០

ប្បវេណីត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលានោះ ចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាសម្រេចឱ្យដើម-បណ្តឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី ។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ ។ ដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះត្រូវឱ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់[15] ។

បណ្តឹងឱ្យជួសជុលការខូចខាតកាលណាការស៊ើបសួរដែលបើកបន្ទាប់ពីមានពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ចូលជាស្ថាពរ បុគ្គលដែលមានឈ្មោះនៅ ក្នុងពាក្យប្តឹងអាចប្តឹងសុំការជួសជុលសំណងពីអ្នកដែលប្តឹងពីខ្លួន ប្រសិនបើនីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា ។ ពាក្យប្តឹងសុំការជួសជុលនេះត្រូវដាក់ជូនដល់តុលាការជាន់ដំបូងដែលរឿងត្រូវបានស៊ើបសួរ ។ តុលាការអាចសុំឱ្យគេបញ្ជូនសំណុំរឿងមកពិនិត្យ[16] ។

**១.៣.៣.វិសាលភាពនៃការប្តឹង**

ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ ។ ប្រសិនបើមានលេចអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះ ទៅព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ ។

ប៉ុន្តែចៅក្រមស៊ើបសួរ មិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេប្រសិនបើអង្គហេតុថ្មីនោះស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង[17] ។ មានន័យថាប្រសិនបើអង្គហេតុដែលចៅក្រមស៊ើបសួរបានរកឃើញថាមានស្ថានទម្ងន់ទោសដូចជា ជនត្រូវចោទបានប្រើប្រាស់អំពើហិង្សាលើបុគ្គលដែលមានមូលហេតុទន់ខ្សោយជាពិសេសដូចជា មានវ័យចំណាស់ នារីមានគភ៌លើកុមារ ដែលត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌនូវស្ថានភាពនៃស្ថានទម្ងន់ទាំងនោះ។ ដូច្នេះចៅក្រមស៊ើបសួរអាចធ្វើការកំណត់អំពីស្ថានទម្ងន់ទោសលើជនត្រូវតាមស្ថានភាពនីមួយៗ។

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៤១

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៤២

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៥

## ១.៤.ការស្នើសុំបំពេញកិច្ចស៊ើបសួរ

### ១.៤.១.ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលានៃការស៊ើបសួរព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរ ណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដីកានេះត្រូវមានសំអាងហេតុហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ទេព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[18] ។ មានន័យថាប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាការស៊ើបសួររបស់ចៅក្រមស៊ើបសួរពុំទាន់មានការសួរទៅលើសាក្សី ឬពុំទាន់បានពិនិត្យលើភស្តុតាងជាឯកសារឬ ធ្វើកោសលវិច័យណាមួយដែលបម្រើដល់ប្រយោជន៍ដល់រឿងក្តីនៅឡើយទេ នោះព្រះរាជអាជ្ញាអាចធ្វើការស្នើសុំបំពេញកិច្ច ឱ្យធ្វើការស៊ើបសួរបន្ថែមដល់ចៅក្រមស៊ើបសួរបានចំពោះកិច្ចណាមួយដែលមានភាពខ្វះចន្លោះ ។ ហើយប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចទៅតាមអ្វីដែលជាការស្នើសុំរបស់ព្រះរាជអាជ្ញានោះទេក្នុងរយៈពេល ១៥ ថ្ងៃទេព្រះរាជអាជ្ញាអាចធ្វើការដាក់ពាក្យសុំទៅសភាស៊ើបសួរឱ្យសម្រេចជំនួសបាន។

### ១.៤.២.ការស្នើសុំបំពេញកិច្ចដោយជនត្រូវចោទ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួនស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីសួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង ។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា ១ (មួយ) ខែបន្ទាប់ពីពេលទទួលពាក្យសុំ ។ ដីកានេះត្រូវតែមានសំអាងហេតុ និងជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១ (មួយ) ខែទេជនត្រូវចោទអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[19] ។

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣២

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៣

### ១.៤.៣.ការស្នើសុំបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី

នៅគ្រប់ពេលវេលានៃការស៊ើបសួរដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរ ឱ្យស្ដាប់ចម្លើយខ្លួនស្ដាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង ។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកា បដិសេធក្នុងចិរវេលា ១ (មួយ) ខែក្រោយពេលទទួលពាក្យសុំ ។ ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា នឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១ (មួយ) ខែទេដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[20] ។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៤

# ជំពូកទី២

# កិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

# ជំពូកទី២

# កិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចក្នុងការស្វែករកភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុក។ បន្ទាប់ពីចៅក្រមស៊ើបសួរមានសមត្ថកិច្ចលើបទល្មើសណាមួយរួចហើយ ចៅក្រមស៊ើបសួរត្រូវប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួននូវក្នុងការស្រាយជ្រាវលើបទល្មើស(**២.១.**) ដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។ លើសពីនេះទៅទៀតប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា មានភាពចាំបាច់ដើម្បីធ្វើការបង្ការកុំឱ្យមាននូវឧបសគ្គផ្សេងៗនៅក្នុងការស៊ើបសួររបស់ខ្លួន ចៅក្រមស៊ើបសួរអាចប្រើប្រាស់នូវវិធានការនិរន្តរាយ (**២.២.**) ក្នុងការសម្រួលការស៊ើបសួររបស់ខ្លួនឱ្យកាន់តែមានភាពល្អប្រសើរ។

## ២.១.វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ជាវិធានការមួយដែលចៅក្រមស៊ើបសួរអាចប្រើប្រាស់ក្នុងការស្រាវជ្រាវរកបទល្មើសដែលបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយព្រះរាជអាជ្ញា។ វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួររួមមាន ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ(**២.១.១.**) ការសួរចម្លើយជនត្រូវចោទ(**២.១.២.**) ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី(**២.១.៣.**) ការស្តាប់ចម្លើយសាក្សី(**២.១.៤.**) ការឆែកឆេរ និងការចាប់យកវត្ថុតាង(**២.១.៥.**) កោសលវិច័យ(**២.១.៦.**) ការស្តាប់ទូរស័ព្ទ(**២.១.៧.**) និងដីកាចាត់ឱ្យស៊ើបសួរជំនួស(**២.១.៨.**)។

### ២.១.១.ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី ។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះចៅក្រមស៊ើបសួរ ត្រូវទទួលចម្លើយនោះភ្លាម ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច ។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី ។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំត្រូវប្រកាសប្រាប់ ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន ។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា:

- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន

- គ្រប់ការឱ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយដែលប្រកាសឡើង ដោយជនត្រូវចោទនោះត្រូវចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់ ។

ការឱ្យដំណឹងព្រមទាំងការប្រកាសស្តីអំពីការផ្លាស់ប្តូរអាសយដ្ឋាននោះ ត្រូវចុះក្នុងកំណត់ហេតុ នៅពេលចូលបង្ហាញខ្លួនលើកដំបូង[21] ។

ជំនួយអ្នកបកប្រែ ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ ។ អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគីឬសាក្សីទេ[22] ។

**២.១.២.ការសួរចម្លើយជនត្រូវចោទ**

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត៥ (ប្រាំ) ថ្ងៃ មុនការសួរចម្លើយ ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី ។ ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវី ។ និទ្ទេសស្តីអំពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ ។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន ។ ការបោះបង់ចោលនេះត្រូវចុះនៅក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ ។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានដែរ ។ ភាពបន្ទាន់នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។ ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែដូចបាន[23] ។ មានន័យថាករណីដែលជនត្រូវចោទមានមេធាវីអម ឬត្រូវបានចាត់តាំងដោយគណៈមេធាវីនោះករណីបែបនេះចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅហើយមេធាវីមានសិទ្ធិក្នុងការពិនិត្យនិងថតចម្លងសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីទទួលបន្ទុក។ ការវាយតំ

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៣

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៤

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៥

លៃលើភស្តុតាងដោយតុលាការ លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី ។ តុលាការថ្លឹងថ្លែងដោយតស្សរចិត្តអំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុភាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ។ ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ ។

បន្ថែមពីលើនេះទៅទៀតចំពោះការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន មិនអាចយកមកធ្វើជាភស្តុតាងបានឡើយ[24] ។

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរ បានដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។ ក្នុងករណីមិនអនុញ្ញាត ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[25] ។

**២.១.៣.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី ។ ក្នុងករណីនេះចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនការស្តាប់ចម្លើយ ។ នៅក្នុងចិរវេលានេះមេធាវីអាចពិនិត្យសំណុំរឿងនីតិវិធីបាន ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវ បានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានវត្តមានរបស់មេធាវី ។ និទ្ទេសស្តីពីអវត្តមាន ត្រូវចុះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ។ ក្នុងករណីពិសេសចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយមិនបាច់កោះហៅមេធាវីប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន ។ ការបោះបង់ចោលនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែកពី កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី ។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីបានដែរ ។ ភាពបន្ទាន់នេះត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីភ័យខ្លាចបាត់បង់តម្រុយភស្តុតាង ។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។ ចៅក្រមស៊ើបសួរអាចហៅរក

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣២១

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៦

អ្នកបកប្រែបានផងដែរ[26] ។ នៅក្នុងពេលស្តាប់ចម្លើយ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរមកសួរ បាន ដោយ មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។ ក្នុងករណីមិនអនុញ្ញាតករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[27] ។

**២.១.៤.ការស្តាប់ចម្លើយសាក្សី**

ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅ ក្នុងការសំដែងឱ្យឃើញការពិត ។ ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។ ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីផងបានដែរ ។ បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឱ្យចូលមកបង្ហាញខ្លួនបាន ។ ចៅក្រមស៊ើបសួរចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន បញ្ជានេះ ត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[28] ។ ទន្ទឹមនិងនេះផងដែរ មុននឹងឆ្លើយទៅនឹងសំណួរសាក្សីម្នាក់ៗ ត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត[29] ។

ក៏ប៉ុន្តែនៅមានស្ថានភាពមួយចំនួនដែលត្រូវបាន ក្រមនីតិវិធីព្រហ្មទណ្ឌលើកលែងឱ្យរួចផុតពីការស្បថដោយបុគ្គលទាំងនោះរួមមាន ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបរបស់ជនត្រូវចោទ បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ បង ប្អូនថ្លៃ ស្រីរបស់ជនត្រូវចោទ ប្តី បប្រពន្ធជនត្រូវចោទ ទោះបីបានលែងគ្នាហើយក៏ដោយ និងកុមារមានអាយុតិចជាង១៤ ឆ្នាំ[30] ។

**២.១.៥.ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ការឆែកឆេរ និងចាប់យកវត្ថុតាង គឺជាវិធានការមួយដែលអនុញ្ញាឱ្យដល់ចៅក្រមស៊ើបសួរក្នុងការអនុវត្តដើម្បីស្វែងរក អំពីពិរុទ្ធភាពរបស់ជនល្មើសដែលបានបង្កគ្រោះថ្នាក់ដល់សង្គមជាតិ និងប៉ះពាល់ដល់ប្រយោជន៍របស់ប្រជាពលរដ្ឋ ។ ហើយចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនចាត់តាំង ។ សាក្សីមិនអាចជានគរ បាល ឬ ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។ ចៅក្រមស៊ើបសួរមិនអាចផ្តើម

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៥០

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៥១

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៥៣

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៥៤

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៥៦

ឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ លើកលែងតែ ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន ឬក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរចែកចាយ ឬប្រើប្រាស់គ្រឿងញៀន ។ ដោយឡែកចំពោះការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ ។ ហើយចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និង ក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) នាក់ ។

បន្ទាប់ចៅក្រមស៊ើបបានចុះទៅធ្វើការឆេកឆេរ ចៅក្រមស៊ើបសួរត្រូវធ្វើ កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។ កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវីនេះ [31]។

ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាង ។ ចៅក្រមស៊ើបសួរត្រូវតែបិទស្លាកបោះត្រាលើវត្ថុតាង ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់ដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីទាំង ២ (ពីរ) នាក់ រួចមកចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្តីពីការចាប់ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក កំណត់ហេតុស្តីពីការចាប់នេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) កំណត់ហេតុត្រូវមាននាក់ ចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។

នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាបើកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា ។ ដីកាសម្រេចត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹង និងមេធាវីនៃអ្នកប្ដឹងប្រសិនបើមាន ។ ហើយចំពោះវត្ថុតាងគឺ មិនគួរប្រគល់សងទៅឱ្យអ្នកប្ដឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់ការ សំដែងឱ្យឃើញការពិត។ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួន បានទេ ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ [32]។

### ២.១.៦.កោសលវិច័យ

#### ២.១.៦.១.ភាពចាំបាច់នៃការធ្វើកោសលវិច័យ

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៥៩

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៦១

ពេលដែលមាន បញ្ហាបច្ចេកទេសចោទឡើងចៅក្រមស៊ើបសួរអាច បង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ដោយចេញដីកាចាត់តាំងអ្នកជំនាញ បញ្ជាក់ពីបេសកកម្មរបស់អ្នកជំនាញ និងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះ ។ កាលណាចៅក្រមស៊ើបសួរបដិសេធ មិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយសំអាងហេតុ ។ ដីកាសម្រេចក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង ១(មួយ) ខែ ប្រសិនបើពាក្យសុំនោះចេញមកពី ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ។ ដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំជាបន្ទាន់[33] ។

**២.១.៦.២.បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ**

ការធ្វើកោសលវិច័យក្នុងករណីដែលជាបទល្មើសព្រហ្មទណ្ឌ ហើយវាមានលក្ខណៈចាំបាច់ដើម្បីបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសនោះគឺ ត្រូវបានបង្កើតឱ្យមានបញ្ជីថ្នាក់ជាតិមួយនៃអ្នកជំនាញ ។ បញ្ជីនេះត្រូវបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ បែបបទនៃការចុះឈ្មោះ ឬលុបឈ្មោះចេញពីបញ្ជីត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីមិនចាំបាច់ស្បថសាជាថ្មីទៀតទេនៅពេលណាខ្លួន ត្រូវបានគេចាត់តាំងឱ្យធ្វើកោសលវិច័យ[34]។ ចៅក្រមស៊ើបសួរតាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ។ ចៅក្រមស៊ើបសួរតាមដីកាដោយមានសំអាងហេតុជាពិសេស អាចចាត់តាំង អ្នកជំនាញដែល**គ្មានឈ្មោះ**នៅក្នុងបញ្ជីថ្នាក់ជាតិបាន ។ ក្នុងករណីនេះអ្នកជំនាញត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការ ស្វែងរកយុត្តិធម៌[35] ។ បានន័យថា បុគ្គលដែលចៅក្រមស៊ើបសួរជ្រើសរើសនោះ គឺពុំមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញដែលបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នោះទេ ពោលគឺត្រូវបានចៅក្រមស៊ើបសួរយល់ឃើញថាបុគ្គលដែលចៅក្រមស៊ើបសួរនោះយល់ឃើញថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចនេះចៅក្រមស៊ើបសួរអាចចេញដីកាដែលមានសំអាងហេតុពិសេសបាន។ នៅក្នុងករណីដែលអ្នកជំនាញត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរដីកាត្រូវបញ្ជាក់អំពីបេសកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេល ត្រូវបំពេញបេសកម្មនេះ។ បេសកម្មអាចទាក់ទងទៅ

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៦២

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៦៣

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៦៤

នឹងបញ្ហា ដែលមានលក្ខណៈបច្ចេកទេស តែប៉ុណ្ណោះ។ ប្រសិនបើជាការគួរចៅក្រមស៊ើបសួរប្រគល់វត្ថុដែលចាប់បានមួយផ្នែកឬទាំងអស់នោះជូនអ្នកជំនាញ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្ដីពីការប្រគល់វត្ថុដែលចាប់បាន ។ អ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសលវិច័យបាន។ ប្រសិនបើកោសលវិច័យនេះ អាចធ្វើឱ្យខូចខាត ឬ វិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញត្រូវជូនព័ត៌មាន ដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះ មុននឹងផ្ដើមប្រតិបត្តិការរបស់ខ្លួន[36]។

នៅក្នុងពេលបំពេញបេសកកម្មរបស់ខ្លួនបានដើម្បីធានាឱ្យមានភាពច្បាស់លាស់អ្នកជំនាញអាច ស្ដាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ ។ ចម្លើយដែលអ្នកជំនាញបានទទួលនោះ មានតម្លៃត្រឹមតែជាព័ត៌មានធម្មតា ។ បុគ្គលដែលអ្នកជំនាញស្ដាប់ចម្លើយនោះមិនបាច់ស្បថទេ ។ ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ត្រូវស្ដាប់ចម្លើយត្រូវចោទ អ្នកជំនាញត្រូវសុំការអនុញ្ញាតពី ចៅក្រមស៊ើបសួរជនត្រូវចោទអាចសុំឱ្យអ្នកជំនាញស្ដាប់ចម្លើយរបស់ខ្លួននចំពោះមុខមេធាវី។ ប៉ុន្តែកាលណាចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬអ្នកចិត្តសាស្ត្រដើម្បីពិនិត្យជនត្រូវចោទនោះការពិនិត្យវេជ្ជសាស្ត្រ ឬ ចិត្តសាស្ត្រត្រូវធ្វើដោយគ្មានវត្តមានមេធាវី[37] ។

### ២.១.៦.៣.របាយការណ៍ និងសោហ៊ុយសម្រាប់ធ្វើកោសលវិច័យ

កាលណាប្រតិបត្តិការកោសលវិច័យបានបញ្ចប់ អ្នកជំនាញធ្វើរបាយការណ៍ដែលនៅក្នុងនោះ ត្រូវពណ៌នាយ៉ាងច្បាស់លាស់អំពីប្រតិបត្តិការរបស់ខ្លួនហើយនិងធ្វើសេចក្ដីសន្និដ្ឋាន ។ អ្នកជំនាញត្រូវបញ្ជាក់ថាបានធ្វើដោយផ្ទាល់ខ្លួននូវប្រតិបត្តិការដែលពណ៌នានៅក្នុងរបាយការណ៍ ។របាយការណ៍ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។ កាលណាអ្នកជំនាញបានបំបែកស្លាកដើម្បីពិនិត្យវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសអំពីបញ្ហានេះនៅក្នុងរបាយការណ៍របស់ខ្លួន ។ កាលណាអ្នកជំនាញប្រគល់របាយការណ៍របស់ខ្លួននោះ អ្នកជំនាញត្រូវប្រគល់ដល់ចៅក្រមស៊ើបសួរវិញនូវវត្ថុដែលចាប់យក ។ ប្រសិនបើស្លាកត្រូវបានបំបែកចៅក្រមស៊ើបសួរត្រូវបិទស្លាកជាថ្មីនៅលើវត្ថុនោះ។ កំណត់ហេតុស្ដីពីការប្រគល់ស្ដី ពីការប្រគល់សងនូវវត្ថុនិងជាយថាហេតុការបិទស្លាកជាថ្មីលើវត្ថុនោះត្រូវធ្វើឡើងវិញ។ កាលណាកោសលវិច័យធ្វើឱ្យ ខូចខាត ឬ វិនាសនូវវត្ថុដែលចាប់បាន អ្នកជំនាញត្រូវចុះនិទ្ទេសនៅក្នុងរបាការណ៍របស់ខ្លួនអំពីការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ ។ ក្នុងករណីដែលអាចធ្វើបាននោះអ្នកជំនាញត្រូវធ្វើសេចក្ដីចម្លងរបាការណ៍ហើយជូនទៅចៅក្រមស៊ើបសួរ[38]។ ទន្ទឹមនឹងនេះផងដែរប្រសិនបើកាលៈទេសៈតម្រូវចៅក្រមស៊ើបសួរអាចចាត់តាំងអ្នកជំនាញច្រើននាក់ ។ នៅក្នុងករណីនេះ

---

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៦៥

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៦៧

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៦៨

ប្រសិនបើអ្នកជំនាញនេះមានយោបល់ខុសគ្នានោះម្នាក់ៗ ត្រូវសរសេរអំពីយោបល់ខ្លួនផ្ទាល់ ឬការមិនយល់ព្រមរបស់ខ្លួន។

កាលណារបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ របាយការណ៍កោសលវិច័យត្រូវដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ ចៅក្រមស៊ើបសួរអាចកោះហៅជនត្រូវចោទ និងមេធាវីដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យនេះ ។ ចៅក្រមស៊ើបសួរអាចកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីផងដែរដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ ។ ចៅក្រមស៊ើបសួរកំណត់រយៈពេលដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យ ។ រយៈពេលនៃការអនុញ្ញាតដាក់ពាក្យស្នើសុំមិនតិចជាង ១០ (ដប់) ថ្ងៃទេ ។ ក្នុងរយៈពេលនេះសំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យ អាចត្រូវបានពិនិត្យមើលដោយមេធាវី [39]។

ដោយឡែកចំពោះសោហ៊ុយសម្រាប់ការធ្វើកោសលវិច័យវិញគឺជាបន្ទុករបស់អ្នកស្នើសុំ មានន័យថា ប្រសិនបើដើមបណ្តឹង ឬជនត្រូវចោទ ស្នើសុំឱ្យធ្វើកោសលវិច័យនោះបន្ទុកត្រូវតែជារបស់ដើមបណ្តឹង ឬជនត្រូវចោទ។ មួយវិញទៀតប្រសិនបើ នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ស្នើសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬធ្វើប្រតិកោសលវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ[40] ។

**២.១.៧.ការស្តាប់ទូរស័ព្ទ**

តាមតម្រូវការចាំបាច់ដើម្បីសំដែងឱ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់និងថតការសន្ទនាតាមទូរស័ព្ទ ។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរសារ ឬសារតាមអិនធើណែត ។ ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត ។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម។ អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ ។ នៅក្នុងពេលអនុវត្តបេសកកម្ម អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការដែលចាត់តាំងត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តិទៅនៃបេសកកម្ម ជាអាទិ៍ អំពីការលំបាកជាយថាហេតុ ។ កាលណាបេសកកម្មត្រូវបានបំពេញរួចហើយអង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំឡេងដែលថតបាន ។ ការ

---

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៧០ កថាខណ្ឌទី៥

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៧១

ធ្វើឱ្យទៅជាលាយលក្ខណ៍អក្សរនេះ ត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសំឡេងដែលថតបាន ។ សំឡេងដែលថតបាននេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក ។

គ្រប់ពេលវេលាចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតនោះ ។ ការចូលទៅក្នុងទីកន្លែងទាំងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាកន្លែងយោធាក៏ដោយ ។ ហើយចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ [41]។

## ២.១.៨.ដីកាចាត់ឱ្យស៊ើបសួរជំនួស

នៅក្នុងអំឡុងពេលនៃការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរអាចនឹងមានការជួបប្រទះនឹងឧបសគ្គផ្សេងៗ ដែលនាំឱ្យចៅក្រមស៊ើបសួរពុំអាចបំពេញភារកិច្ចដោយខ្លួនឯងបាន ដែលជាហេតុនាំឱ្យចៅក្រមស៊ើបសួរប្រគល់សិទ្ធិឱ្យអ្នកផ្សេងដែលជាមន្ត្រីដែលមានសមត្ថកិច្ចដើម្បីបំពេញកិច្ចស៊ើបសួរ ។ តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមានន័យថាជាប្រតិភូកម្មនៃអំណាចដែលចៅក្រមស៊ើបសួរប្រគល់ឱ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាល ឬអង្គភាពនគរបាលយុត្តិធម៌ដើម្បីអនុវត្តកិច្ចស៊ើបសួរ។

នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើកិច្ចនោះ ត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាច មានលក្ខណៈជាទូទៅទេ ត្រូវណែនាំឱ្យបានច្បាស់លាស់ ។ ចៅក្រមស៊ើបសួរកំណត់ថិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះកាលបរិច្ឆេទចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។ ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា ។ មានន័យថា នៅពេលដែលចៅក្រមស៊ើបសួរបានចេញដីកាឱ្យស៊ើបសួរជំនួសនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើការគោរព និងប្រតិបត្តតាមអ្វីដែលបានកំណត់នៅក្នុងខ្លឹមសារនៃដីកាចាត់ឱ្យស៊ើបជំនួសនោះ ។ ស្របពេលជាមួយគ្នានេះផងដែរមន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី ។ មុននឹងឆ្លើយចំពោះសំណួរសាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត ។ ដើម្បីគោរពសិទ្ធិការពារខ្លួនមន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ ។ បាន

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៧២

សេចក្តីថាបើបុគ្គលជាជនល្មើសត្រូវបាន គេសង្ស័យដោយមានការចូលរួមប្រព្រឹត្តបទល្មើសនោះមន្រ្តីនគរបាលយុត្តិធម៌មិនអាចធ្វើការស្តាប់ចម្លើយជាសាក្សីដែលមានតម្រុយពិរុទ្ធភាពបានទេ ។ កាលណាការស្តាប់ចម្លើយសាក្សីណាម្នាក់ បានធ្វើឱ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែដែលបានស្បថស្រប តាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងជួយបកប្រែជូនតុលាការឱ្យបានត្រឹមត្រូវ ។

មួយវិញទៀតប្រសិនបើ បុគ្គលដែលបានកោះហៅក្នុងឋានៈជាសាក្សីត្រូវតែចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជូនចៅក្រមស៊ើបសួរដែលអាចចេញបញ្ជាឱ្យចូលខ្លួនដោយមាន ចុះអត្តសញ្ញាណនៃសាក្សី បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងបញ្ជាឱ្យចូលបង្ហាញខ្លួនអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំឱ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន ។

ក៏ប៉ុន្តែនៅក្រមនីតិវិធីព្រហ្មទណ្ឌបានហាមឃាត់លើមន្ត្រីនគរបាលយុត្តិធម៌ មិនអាចសួរចម្លើយជនត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ[42] ។

## ២.២.វិធានការនិរន្តរាយ

វិធានការនិរន្តរាយជាយន្តការមួយដែលចៅក្រមស៊ើបសួរ អាចប្រើប្រាស់ដើម្បីទប់ស្កាត់កុំឱ្យមានការលំបាកដល់កិច្ចស៊ើបសួររបស់ខ្លួន ។ ប្រសិនបើមានភាពចាំបាច់ដើម្បីរក្សាទុកនូវភស្តុតាង ឬដើម្បីរក្សាជនត្រូវចោទទុកចំពោះមុខយុត្តាធិការជំនុំជម្រះដើម្បីផ្តន្ទាទោស នោះចៅក្រមស៊ើបសួរអាចប្រើប្រាស់នូវវិធានការនិរន្តរាយដោយចេញវិធានការនិរន្តរាយស្របតាមស្ថានភាពនីមួយៗ ។ អនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីសម្រួលដល់កិច្ចស៊ើបសួរឱ្យប្រព្រឹត្តទៅឱ្យបានល្អ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន(**២.២.១.**) ដីកាបង្គាប់ឱ្យនាំខ្លួន(**២.២.២**) ដីកាបង្គាប់ឱ្យចាប់ខ្លួន(**២.២.៣.**) ការឃុំខ្លួនបណ្តោះអាសន្ន(**២.២.៤.**)[43] និងការដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ(**២.២.៥.**) ។

### ២.២.១.ដីកាបង្គាប់ឱ្យចូលខ្លួន

#### ២.២.១.១.អត្ថន័យ

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ។ ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ ។ ដីកាបង្គាប់ឱ្យចូលខ្លួនអាចចេញទៅលើជនត្រូវចោទ ឬ

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៨០
[43] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៨៥

ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[44] ។ មានន័យថាប្រសិនបើចៅក្រមស៊ើបសួរត្រូវការស្តាប់ចម្លើយទៅលើជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួនបាន។

**២.២.១.២.និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យចូលខ្លួន**

ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសដូចខាងក្រោម៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនិងមានបោះត្រាផង [45] ។ បន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចដោយផ្អែកទៅលើឆន្ទានុសិទ្ធិរបស់ខ្លួនចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួន ដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា ។ បានន័យថាការឱ្យដំណឹងនោះគឺត្រូវធ្វើឡើងដោយមន្ត្រីនរគបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាល ជាអ្នកបញ្ជូនដំណឹងដែលត្រូវបញ្ជូននោះទៅបុគ្គលដែលចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចូលខ្លួន ។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកាហើយត្រូវចុះហត្ថលេខានៅលើដើមដីកាដែលត្រូវ បង្វិលជូនចៅក្រមស៊ើបសួរវិញ ។ មន្ត្រីនគរបាលយុត្តិធម៌ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ អំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន[46] ។

**២.២.២.ដីកាបង្គាប់ឱ្យនាំខ្លួន**

**២.២.២.១.អត្ថន័យ**

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ។ ដីកាបង្គាប់ឱ្យនាំខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព [47]។ មានន័យថាចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនភ្លាមដោយពុំចាំបាច់ធ្វើការកោះហៅឱ្យចូលដើម្បីឆ្លើយបំភ្លឺជាមុនទេ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាវាមានភាពចាំបាច់ ។

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៨៦

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៨៧

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៨៨

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩០

**២.២.២.២.និទ្ទេសដែលចៅក្រមស៊ើបសួរត្រូវចុះលើដីកាបង្គាប់ឱ្យនាំខ្លួន**

និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួនមាននិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។ ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង មានបោះត្រាផង[48] ។

**២.២.២.៣.ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន**

ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកានេះ ត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាល យុត្តិធម៌ដែលទទួលបន្ទុកអនុវត្តការនោះ ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋាន របស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបីល្ងាច) បានទេ ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការ អនុវត្តបេសកកម្មរបស់ខ្លួន [49] ។

ជាគោលការណ៍នៅពេលដែលមានដីកាបង្គាប់ឱ្យនាំខ្លួន នោះជនត្រូវចោទត្រូវនឹងត្រូវបាននាំខ្លួនទៅបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ក៏ប៉ុន្តែប្រសិនបើដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួន ដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ ។ បុគ្គលនេះត្រូវតែខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួស។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ[50] ។ កាលណាបុគ្គលណាម្នាក់ ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវបានឃុំខ្លួននោះចិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន[51] ។ បានន័យថាអំឡុងពេលដែលពុំអាចបញ្ជូនជននោះទៅបង្ហាញមុខនៅចំពោះមុខចៅក្រមស៊ើបសួរ ហើយបានរក្សាជននោះនៅក្នុងពន្ធនាគារ ឬ

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩១

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩២

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩៣

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩៤

មណ្ឌលឃុំខ្លួន អំឡុងពេលដែលត្រូវឃុំនោះនឹងត្រូវគិតបញ្ចូលជាមួយនឹងអំឡុងពេលឃុំខ្លួនបណ្តោះអាសន្ន ដែលជាមូលដ្ឋានមួយក្នុងការផ្តល់ឱកាសឱ្យជនត្រូវចោទបានឆាប់ចេញពីពន្ធនាគារវិញ ។

**២.២.៣.ដីកាបង្គាប់ឱ្យចាប់ខ្លួន**

**២.២.៣.១.អត្ថន័យ**

ដីកាបង្គាប់ឱ្យចាប់ខ្លួនគឺជាការបញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ [52] ។

**២.២.៣.២.លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន**

ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបាន លុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទ ឬបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព។
- បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។
- បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។
- ចៅក្រមស៊ើបសួរបានទទួលយោបល់ព្រះរាជអាជ្ញាលើបញ្ហាចាប់ខ្លួននេះ នៅមុនពេលចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរចេញដីកាបញ្ជូនឱ្យឆ្លើយដើម្បីឱ្យព្រះរាជអាជ្ញាផ្តល់យោបល់ពីការបង្គាប់ឱ្យចាប់ខ្លួន ប៉ុន្តែយោបល់របស់ព្រះរាជអាជ្ញាពុំមានអានុភាពចងចៅក្រមស៊ើបសួរឱ្យធ្វើតាមនោះទេ ព្រះរាជអាជ្ញា ជាអ្នកធានារ៉ាប់រងការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួនហើយមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន[53] ។

**២.២.៣.៣.និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចាប់ខ្លួន**

និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចាប់ខ្លួនរួមមាន៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលត្រូវចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសនេះ
- ឈ្មោះនិងឋានៈចៅក្រមដែលចេញដីកា។ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថ

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩៦ កថាខណ្ឌទី៣

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩៦ និងមត្រា១៩៧

លេខាដោយចៅក្រមស៊ើបសួរ និងបោះត្រាផង[54] ។

**២.២.៣.៤.ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន និងការបង្ហាញខ្លួនរបស់ជនពាក់ព័ន្ធ**

ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌[55]។

ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលក្នុងលំនៅឋានរបស់បុគ្គលពាក់ព័ន្ធមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចនោះឡើយ[56] ។ ដីកាបង្គាប់ឱ្យចាប់ខ្លួនគឺអាចធ្វើឡើងនៅក្នុងស្ថានភាពដែលជនត្រូវចោទបានរត់គេចខ្លួនបន្ទាប់ពីមានដីកាបង្គាប់ឱ្យចាប់ខ្លួន ហើយជនត្រូវចោទដែលបានប្រព្រឹត្តបទ-ល្មើសមជ្ឈិម ឬបទឧក្រិដ្ឋ ហើយជនដែលពាក់ព័ន្ធនោះមិនដឹងគេចខ្លួនទៅទីកន្លែងណា ។ ក្នុងករណីចាប់បាច់ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌បាន ដោយប្រើយន្តការនានាដែលមានប្រសិទ្ធិភាព[57]។

ទន្ទឹមនិងនេះផងដែរជនដែលពាក់ព័ន្ធ និងត្រូវបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួនដោយត្រូវបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួនដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬចុងដីកាដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។ បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ ។ ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះ តម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀត ការផ្ទេរនេះត្រូវចាត់ចែងដោយអយ្យការ ។ ប្រសិនបើបុគ្គលពាក់ព័ន្ធមិនត្រូវ បានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនបុគ្គលនេះត្រូវតែ បានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ។ ព្រះរាជអាជ្ញានេះធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ ដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ[58]។ ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួនដោយអនុវត្ត

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩៨

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩៩ កថាខណ្ឌទី១

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៩៩

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០០

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០១

តាមដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវបានឃុំខ្លួននោះ ថិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នប្រសិនបើមាន[59]។

**២.២.៤.ការឃុំខ្លួនបណ្ដោះអាសន្ន**

ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព[60] ។ បានន័យថាសិទ្ធិសេរីភាពរបស់ជនត្រូវចោទត្រូវតែមានដល់ជនត្រូវចោទលើកលែងតែករណីពិសេស ឬករណីដែលចៅក្រមស៊ើបសួរមានមូលហេតុចាំបាច់ណាមួយទើបអាចឃុំខ្លួនជនត្រូវចោទបាន ។ ការឃុំខ្លួនគឺជាការរឹតត្បិតសិទ្ធិសេរីភាពរបស់ជនត្រូវចោទ ហើយពុំអាចមានសេរីភាពក្នុងការធ្វើសកម្មភាពផ្សេងៗ បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន និងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ។ ពេលដែលចៅក្រមស៊ើបសួរបានសួរចម្លើយលើជនត្រូចោទ ឬបានដាក់ឱ្យស្ថិតក្រោមការពិនិត្យរួចហើយ ចៅក្រមស៊ើបសួរត្រូវពិចារណា ក្នុងការសម្រេឃុំខ្លួនបណ្ដោះអាសន្ន (**២.២.៤.១.**) រួមទាំងពិនិត្យលើលក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន(**២.២.៤.២.**) និងមូលហេតុនៃការឃុំខ្លួនផងដែរ(**២.២.៤.៣.**) ។ លើសពីនេះទៅទៀតបន្ទាប់ពីសម្រេចថាខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទចៅ-ក្រមស៊ើបសួរត្រូវធ្វើឡើងស្របតាមបញ្ញត្តច្បាប់ ពោលគឺការឃុំខ្លួនបណ្ដោះត្រូវស្របតាមថិរវេលាដែលច្បាប់បានកំណត់(**២.២.៤.៤.**) ហើយចំពោះការប្រតិបត្តិនៃការឃុំខ្លួន(**២.២.៤.៥.**) ត្រូវធ្វើឡើងតាមរយៈអាជ្ញាធរពន្ធនាគារក្នុងការទទួល និងឃុំខ្លួនជនត្រូវចោទដោយស្របច្បាប់ ។

**២.២.៤.១.ការសម្រេចលើការឃុំខ្លួនបណ្ដោះអាសន្ន**

ប្រសិនបើចៅក្រមស៊ើបសួរ **សម្រេចមិនឃុំខ្លួនជនត្រូវចោទ** ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឱ្យជននោះត្រឡប់ទៅផ្ទះវិញបន្ទាប់ពីមានការដាក់ឱ្យស្ថិតក្រោមការពិនិត្យ ឬសួរចម្លើយរួចហើយ [61]។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាបានស្នើសុំឱ្យចៅក្រមស៊ើបសួរឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន (ការស្នើសុំដោយផ្ទាល់មាត់ នាពេលដែលមានការពិភាក្សាដេញដោលពីបញ្ហាឃុំខ្លួន ឬធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ) ហើយចៅក្រមស៊ើបសួរបានសម្រេចថាពុំត្រូវឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវចេញ **ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះសន្ន** ដោយពុំចាំបាច់មានសំអាងហេតុទេ [62] ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំពោលគឺព្រះរាជអាជ្ញា ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃព្រះរាជ

---

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០២

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០៣

[61] សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៨,ទំព័រ៣៨

[62] សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៨,ទំព័រ៣៨

អាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ[63] ។

ប្រសិនបើចៅក្រមស៊ើបសួរយល់ថា **ត្រូវឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន** ចៅក្រមស៊ើបសួរត្រូវចេញដីកាចំនួនពីគឺ **ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន** និង **ដីកាបង្គាប់ឱ្យឃុំខ្លួន**[64]។ ដីកាសម្រេចជាសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បាន។ ចំណែកឯដីកាបង្គាប់ឱ្យឃុំខ្លួនវិញគ្រាន់តែជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំជនត្រូវចោទប៉ុណ្ណោះហេតុនេះដីកាបង្គាប់ឱ្យឃុំខ្លួនពុំអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បានទេ[65] ។ ក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានការចុះនិទ្ទេសដូចជា៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[66] ។ បន្ទាប់ពីមានដីកាបង្គាប់ឱ្យឃុំខ្លួនប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[67]។ ប្រសិនបើចៅក្រមស៊ើបសួរមិនចុះហត្ថលេខា និងបោះត្រាវានឹងធ្វើឱ្យប៉ះពាល់សិទ្ធិរបស់ជនត្រូវចោទ ហេតុហើយជនត្រូវចោទអាចធ្វើការប្តឹងសុំមោឃភាពនៃកិច្ចនីតិវិធីបាន ។ មួយវិញទៀតបើការសម្រេចថាត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន[68] ។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន តាមដីកាដោយមានសំអាងហេតុ ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

---

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០៧ កថាខណ្ឌទី២

[64] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌរបស់សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១៨,ទំព័រ៣៨

[65] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌរបស់សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១៨,ទំព័រ៣៨

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២២១

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២២២

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៦៦

**២.២.៤.២.លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន**

ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នបានគឺស្ថិតនៅក្នុងករណីដូចខាងក្រោម៖

(១).ការឃុំខ្លួនបណ្ដោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ (មួយ) ឆ្នាំ[69] ។ បានន័យថាការឃុំខ្លួនអាចធ្វើទៅបានលុះត្រាតែបទល្មើសនោះគឺជាបទល្មើសមជ្ឈិម ឬបទឧក្រិដ្ឋ[70] បានដោយចៅក្រមធ្វើការពិរណាអំពីទោសដាក់ពន្ធនាគារដែលបានកំណត់ថា ស្មើ ឬលើស ១ (មួយ) ឆ្នាំ ដូចនេះប្រសិនបើពន្ធល្មើសដែលបានផ្ដន្ទាទោសដាក់ពន្ធនាគារតិចជាង១ (មួយ)ឆ្នាំ ឬបទល្មើសពិន័យជាប្រាក់ពុំអាចធ្វើការឃុំខ្លួនបណ្ដោះអាសន្នបានទេ។

**២.២.៤.៣.មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន**

ចៅក្រមស៊ើបសួរមុននឹង ឈានទៅដល់ការឃុំខ្លួនបណ្ដោះអាសន្នត្រូវតែយោង ទៅតាមមូលហេតុណាមួយដែលយល់ថាចាំបាច់ក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។ ដោយមូលហេតុទាំងនោះគឺត្រូវតែមានភាពចាំបាច់ក្នុងការឃុំខ្លួន ហើយមូលហេតុទាំងនោះរួមមាន៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី
- ដើម្បីរារាំងកុំឱ្យមានការគៀបសង្កតលើសាក្សី ឬជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស [71] ។

**២.២.៤.៤.ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន**

ប្រសិនបើចៅក្រមស៊ើបសួរបានសម្រេចថាឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ការឃុំខ្លួនជាបណ្ដោះ-អាសន្ននេះត្រូវស្ថិតក្នុងថិរវេលាដែលច្បាប់បានកំណត់ ។ ហើយថេរវេលានៃការឃុំខ្លួននីមួយៗត្រូវអនុលោមទៅតាមចំណាត់ថ្នាក់ ឬប្រភេទនៃបទល្មើសដែលបានចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទ ។ បន្ទាប់ពីថិរវេលាដែលបានឃុំខ្លួនកន្លងផុត ទៅចៅក្រមស៊ើបសួរក៏អាចពន្យាពេលនៃការឃុំខ្លួនជនត្រូវចោទបានផងដែរ មានន័យ

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០៤

[70] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៦,៤៧

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០៥

ថាចៅក្រមស៊ើបសួរអាចពន្យាពេលបន្ថែមពីលើបទល្មើសទៅតាមរយៈពេលនៃច្បាប់កំណត់ ដោយពុំអាចពន្យាពេលលើសពីរយៈពេលនៃច្បាប់កំណត់បានទេ ហើយចំពោះថិរវេលានៃការឃុំខ្លួន និងការពន្យាការឃុំខ្លួនមានដូចតទៅ៖

**ក.ករណីជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ**

ក្នុងករណីដែលបទល្មើសត្រូវបានចោទប្រកាន់ចំពោះជនត្រូវចោទពីបទ ***បទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាម*** ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី១(មួយ) ឆ្នាំបានទេចំពោះបទ ល្មើសនីមួយៗ ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបាន១(មួយ) ឆ្នាំ ដោយដីកាសម្រេចមានសំអាងហេតុ ហើយការពន្យាពេលនេះអាចធ្វើបានតែ ២ (ពីរ) ដងគត់[72] ។

**ខ.ករណីជាប់ចោទពីបទឧក្រិដ្ឋផ្សេងៗ**

- **ករណីជនជាប់ចោទជានីតិជន**

ចំពោះអនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី៦(ប្រាំមួយ)ខែបានទេ ។ ប៉ុន្តែនៅពេលផុតថិរវេលានេះចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួននោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នគឺមានរយៈពេល ៦ខែហើយអាចពន្យាពេលបាន ៦ខែទៀតចំនួនពីរដងដោយមានសំអាងហេតុច្បាស់ លាស់[73]។

- **ករណីជនជាប់ចោទជាអនីតិជន**

ក្នុងករណីដែលជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ ១៦ឆ្នាំ នោះរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ខែបាននោះទេ។ ដោយឡែកនៅក្នុងករណីដែលជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ នោះរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ខែបាននោះទេ[74] ។

ស្របពេលជាមួយគ្នានេះផងដែរចំពោះអនីតិជនអាយុតិចជាង១៤ (ដប់បួន) មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ ។ មានន័យថា ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាលត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរង់ចាំសេចក្តីសម្រេច

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១០

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០៨

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៣

របស់តុលាការ[75] ។ មួយវិញទៀតក្រមព្រហ្មទណ្ឌគឺបានកំណត់អំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានអាយុ១៨ ឆ្នាំឡើងទៅ ប៉ុន្តែចំពោះអនីតិជនអាយុក្រោម ១៨ឆ្នាំ ពោលគឺមានអាយុចាប់ពី១៤ឆ្នាំឡើងទៅ ប្រសិនបើប្រព្រឹត្តបទល្មើសគឺជាកម្មវត្ថុនៃវិធានការតាមដាន វិធានការឧបត្ថម្ភ វិធានការការពារ និងវិធានការអប់រំ។ ប៉ុន្តែបើកាលទេសៈ ឬបុគ្គលិកលក្ខណៈអនីតិជននោះតម្រូវ អនីតិជននោះនឹងទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ[76]។ ហេតុនេះហើយទើបចៅក្រមស៊ើបសួរ ពុំអាចឃុំខ្លួនបណ្តោះអាសន្នលើអនីតិជនដែលមានអាយុតិចជាង១៤ ឆ្នាំ បានដោយសារតែអនីតិជននោះពុំទទួលខុសត្រូវព្រហ្មទណ្ឌទេ។

**គ.ករណីជាប់ចោទពីបទមជ្ឈិម**

- **ករណីជនជាប់ចោទជានីតិជន**

ចំពោះអនីតិជនដែលជាប់ចោទពីបទមជ្ឈិម រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នគឺ ៤ខែ ហើយអាចពន្យាពេលបាន២ខែទៀត តែម្តងគត់ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួន បណ្តោះអាសន្ននេះពុំអាចលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[77]។ ឧទាហរណ៍ ជនត្រូវចោទជាប់ចោទពីបទ ***ហិង្សាចេតនាលើអ្នកដទៃ*** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់៣ ឆ្នាំ (មាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ) អប្បបរមានៃទោស គឺ១ឆ្នាំ ដូចនេះពាក់កណ្តាលនៃអប្បបរមាគឺ ៦ខែ។ មានន័យថាការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវឱ្យលើសពី ៦ខែឡើយ។ ចំណែកឯបទល្មើស ទទួលផលចោរកម្ម វិញត្រូវបានច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ (មាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ)។ ហេតុនេះពាក់កណ្តាលនៃអប្បបរមានៃទោសគឺ ១ឆ្នាំ។ ដូច្នេះមានន័យថា ការឃុំខ្លួនបណ្តោះអាសន្នគឺ ៤ខែ ហើយចៅក្រមស៊ើបសួរអាចពន្យាពេលបានបន្ថែម ២ខែទៀតតែម្តងគត់ ជាសរុបមិនឱ្យលើសពី ៦ខែឡើយ (ក្នុងករណីនេះ ៦ខែ គឺតិចជាង ១ ឆ្នាំ ដែលជាចំនួនពាក់កណ្តាលអប្បបរមានៃទោសដែលកំណត់ដោយច្បាប់សម្រាប់បទ ទទួលផលចោរកម្ម) ។

- **ករណីជនជាប់ចោទជាអនីតិជន**

ក្នុងករណីដែលជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំដល់ក្រោម ១៦ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២ខែ បានទេបើទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួន បណ្តោះអាសន្ននេះពុំអាចលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ ។ ម្យ៉ាងទៀតក្នុងករណីដែលជនត្រូវចោទមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ រយៈ ពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះពុំអាចលើសពី

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១២
[76] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៩ កថាខណ្ឌទី២
[77] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២០៩

៤ខែបានទេ ហើយទោះជាយ៉ាងណារយៈ ពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ពុំអាចលើសពីពាក់កណ្ដាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[78] ។ តាមការបកស្រាយខាងលើមកឃើញថារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចពន្យារបានឡើយ ប្រសិនបើជនត្រូវចោទជាអនីតិជនទោះបីជាត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋឬមជ្ឈិមក៏ដោយ។

**ឃ.ការដោះលែងជនត្រូវចោទ**

ការដោះលែងជនត្រូវចោទដែលត្រូវបានជាប់ឃុំខ្លួនបណ្ដោះអាសន្នគឺចៅក្រមស៊ើបសួរអាចធ្វើការដោះលែងជនត្រូវចោទឱ្យមានសេរីភាពឡើងវិញដោយ អនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌគឺមាន ៣ យ៉ាង៖

(១) ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ៖ ក្នុងករណីនេះចៅក្រមស៊ើបសួរចេញដីកាបញ្ជូនឱ្យឆ្លើយដើម្បីសុំយោបល់ព្រះរាជអាជ្ញា ទាក់ទិននឹងបំណងរបស់ចៅក្រមក្នុងការដោះលែងជនត្រូវចោទឱ្យមានសេរីភាពវិញ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេល៥ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងមកខ្លួន ។ ជាធម្មតាចៅក្រមស៊ើបសួរត្រូវរង់ចាំយោបល់ពីព្រះរាជអាជ្ញាសិន មុននឹងសម្រេចថាដោះលែងជន ត្រូវចោទ ប៉ុន្តែក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងភ្លាម ដោយចង្អុលប្រាប់ពីមូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន[79] ។ ចៅក្រមស៊ើបសួរចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ។ មូលហេតុនៃការបន្ទាន់មាន ឧទាហរណ៍ដូចជាជនត្រូវចោទត្រូវការបញ្ជូនទៅព្យាបាលនៅបរទេសភ្លាមដោយមិនអាចរង់ចាំបានយោងទៅលើស្ថានភាពជម្ងឺធ្ងន់ធ្ងររបស់ជនត្រូវចោទ ហើយពុំអាចព្យាបាលនៅក្នុងប្រទេសបានជាដើម ហើយយោបល់របស់ព្រះរាជអាជ្ញាពុំចងឱ្យចៅក្រមស៊ើបសួរសម្រេចតាមនោះទេ ។

(២) ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា៖ ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ថាយល់ព្រមដោះលែងឱ្យនៅក្រៅឃុំ ឬមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេលកំណត់នេះទេ ព្រះរាជអាជ្ញាអាចប្ដឹងទៅសភាស៊ើបសួរដើម្បីសម្រេចជំនួស ។ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ។ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែមានសំអាងហេតុ[80] ។

(៣) ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ ឬមេធាវីជនត្រូវចោទ៖ ជន

---

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៤

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៥

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៦

ត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរ បញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញាដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១ (មួយ) ខែបន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន ។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។ ដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ [81] ។

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទ នោះចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីដីកាដោះលែងឱ្យនៅក្រៅឃុំ ។ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធាន ពន្ធនាគារ ឬមណ្ឌលឃុំខ្លួន [82] ។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្តោះអាសន្នជនត្រូវចោទនោះ ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ ***រហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍*** របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាម សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញាត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី [83]។ ដីកាមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទហើយ កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំចៅក្រមនេះអាចដាក់ជននោះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន[84] ។

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោស ដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា[85] ។ មានន័យថាការដែលតុលាការបានធ្វើការប្រកាសទោសណាមួយចំពោះទណ្ឌិត ថិរវេលាដែលបានឃុំខ្លួនត្រូវគិត

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៧

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៨ កថាខណ្ឌទីវាក្យខណ្ឌទី១

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៨ កថាខណ្ឌទីវាក្យខណ្ឌទី១,មាត្រា២៧៦ កថាខណ្ឌទី១

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៨

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៥០៣

បញ្ចូលចំពោះ ទោសដែលត្រូវអនុវត្ត ពោលគឺមិនអនុវត្តពេញលេញទៀតនោះទេ។

**២.២.៤.៥.ការប្រតិបត្តិនៃការឃុំខ្លួនបណ្តោះអាសន្ន**

បន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនលើបុគ្គលជាជនត្រូវចោទដោយផ្អែកតាមលក្ខខណ្ឌ និងមូលហេតុដែលបានរៀបរាប់ខាងលើរួចហើយ នោះភ្នាក់ងារពន្ធនាគារអាចទទួល និងឃុំខ្លួនជនត្រូវចោទបាន ។

**ក.លិខិតឃុំខ្លួន**

បន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ភ្នាក់ងាររដ្ឋបាលពន្ធនាគារអាចទទួល និងឃុំខ្លួនដោយផ្អែកលើដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នបាន ។ ផ្ទុយទៅវិញប្រសិនបើភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលបានទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការទេនោះ ត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់[86] ។

បន្ថែមពីនេះទៅទៀតគ្រប់ពន្ធនាគារ និងមណ្ឌលឃុំខ្លួនទាំងអស់ **ត្រូវមានបញ្ជីមួយ** ដែលចុះនិទ្ទេសអំពីអត្តសញ្ញាណបុគ្គលឃុំខ្លួនកាលបរិច្ឆេទឃុំខ្លួន និងកាលបរិច្ឆេទដោះលែងបញ្ជីនេះត្រូវបានត្រួតពិនិត្យជារឿយៗដោយអយ្យការ ។ ទំព័រនីមួយៗ ត្រូវតែចុះទិន្នាការដោយអយ្យការ ។ គ្រប់ភ្នាក់ងារនៃរដ្ឋបាលពន្ធនាគា និងមណ្ឌលឃុំខ្លួន ត្រូវតែជូនបញ្ជីទៅចៅក្រមពិនិត្យមើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមការ ប្រគល់អំណាចពីអាជ្ញាធរតុលាការ [87] ។

**ខ.ការផ្តល់ដំណឹងដល់ព្រះរាជអាជ្ញាក្នុងករណីមានឧប្បត្តិហេតុធ្ងន់ធ្ងរ**

គ្រប់ឧប្បត្តិហេតុធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ ក្នុងមណ្ឌលឃុំខ្លួន ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ។ ក្នុងករណីដែលអ្នកទោសរត់ចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួននោះព្រះរាជអាជ្ញាចេញបញ្ជា ស្វែងរកចាប់ខ្លួន និងចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តបញ្ជាស្វែងរកចាប់ខ្លួន[88] ។ ឧទាហរណ៍ ក ត្រូវបានប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈស្របតាមបញ្ញត្តិនៃមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ទៅ ១០ឆ្នាំ ដោយហេតុថា ការដែលបុគ្គល ក បានប្រព្រឹត្តអំពើខាងលើដែលមានលក្ខណៈធ្ងន់ធ្ងរខ្លាំងពេកចៅក្រមស៊ើបសួរក៏បានសម្រេចឃុំខ្លួនបណ្តោះអាសន្ន ហើយជនជាប់ឃុំ[89] ក បានរត់គេចពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

---

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៥០៦ កថាខណ្ឌទី២

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៥០៥

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៥១១

[89] ជនជាប់ឃុំសំដៅលើ ជនត្រូវចោទ ឬជនជាប់ចោទ ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតចេញដោយអាជ្ញាធរតុលារការ, ច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១៤, មាត្រា៤ ចំណុចទី៣

ក្នុងករណីនេះភ្នាក់ងាររដ្ឋបាលពន្ធនាគារត្រូវរាយការណ៍ទៅព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាអាចចេញបញ្ជា ឱ្យចាប់ខ្លួនលើជនជាប់ឃុំនោះបាន។

### ២.២.៥.ការដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួន ឬដោះលែងជនត្រូវចោទឱ្យជនត្រូវចោទនៅក្រៅឃុំចៅក្រមស៊ើបសួរអាចដាក់ឱ្យជននោះស្ថិតនៅក្រោមការត្រួតពិនិត្យ ដោយតម្រូវឱ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬច្រើនតាមការកំណត់របស់ក្រមនីតិវិធីបាន ។ ចៅក្រមស៊ើបសួរពុំអាចដាក់ជនត្រូវចោទដែលជាអនីតិជនមានអាយុក្រោម ១៤ឆ្នាំ ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[៩០] ពោលគឺអនុវត្តបានចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទៅតែប៉ុណ្ណោះ។

#### ២.២.៥.១.ប្រភេទនៃដីកាសម្រេចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលារ

នៅពេលចៅក្រមស៊ើបសួរបានសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ឱ្យជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ ។

២-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៦-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ។

៧-មិនត្រូវបើកបររថយន្ត ។

៨-មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ ។

៩-ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ ។

១០-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី នូវអាវុធដែលជនត្រូវចោទកាន់កាប់ ។

---

[៩០] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២២៤

១១-ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ ។

ដើម្បីអនុវត្តចំណុចទី ១២ ខាងលើចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ[91]។

**២.២.៥.២.ដីកាសម្រេចដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមគំនិតផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ ។ ដីកាសម្រេចដាក់ខ្លួនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។ កាលណាចៅក្រមស៊ើបសួរដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញា សុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនព្រមសម្រេចតាមការសុំទេចៅក្រមស៊ើបសួរ ត្រូវចេញដីកាបដិសេធការសុំនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ [92]។

**ក.ការកែការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរដោយព្រះរាជអាជ្ញា ឬជនត្រូវចោទ**

ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការដោយឯកឯង អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មី បានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកា ដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ [93]។

បណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា ព្រះរាជអាជ្ញាអាចសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិន

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២២៣

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២២៦

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២២៧

បានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាដែលសម្រេចមិនព្រមធ្វើតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញា ត្រូវតែមានសំអាងហេតុ [94] ។

បណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ ជនត្រូវចោទអាចធ្វើពាក្យសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យសុំនេះភ្លាមទៅព្រះរាជអាជ្ញាដើម្បីសុំយោបល់ និងជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុង រយៈពេល ៥ (ប្រាំ) ថ្ងៃគិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

កាលណាមានពាក្យសុំឱ្យលើកលែង ឬឱ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មី មុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេល ៥ (ប្រាំ) ថ្ងៃនេះត្រូវចាប់ផ្តើមគិតពីពេលចេញ សេចក្តីសម្រេចលើពាក្យសុំពីមុន។ ដីកាដែលសម្រេចមិនព្រមធ្វើតាមពាក្យសុំត្រូវតែមានសំអាងហេតុ ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនេះទេជនត្រូវចោទ អាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ [95]។

### ខ.ការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែល ត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទ ត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាចំពោះបទល្មើសអ្វីក៏ដោយ ដែលជាបទល្មើសផ្តន្ទាទោសដាក់ពន្ធនាគារ ។

កាលណាចៅក្រមស៊ើបសួរសម្រេចថា នឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវជូនមធ្យោបាយការពារកូនក្តីរបស់ខ្លួន។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទតាមដីកាដែលមានសំអាងហេតុ ។ ដីកាសម្រេចនេះត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។ ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមករណីនេះ មិនអាចឱ្យលើសពី ៤ (បួន) ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន [96]។ បានសេចក្តីថា នៅពេលដែលចៅក្រមស៊ើបសួរបានសម្រេចដាក់ឱ្យជនត្រូវចោទត្រូវ

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២២៨

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២២៩

[96] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៣០

គោរពនូវកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ហើយជនត្រូវចោទនោះពុំមានការធ្វើតាម ពោលគឺមានការគេចវេះ នៅក្នុងករណីបែបនេះចៅក្រមស៊ើបសួរអាច សម្រេចឃុំខ្លួនបណ្ដោះអាសន្នបាន។ ហើយទោះបីជាជនត្រូវចោទនោះបានឃុំខ្លួនអតិបរមានៃបទល្មើសអ្វីក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែអាចឃុំខ្លួនជនត្រូវចោទនោះបាន។

# ជំពូកទី៣
# ការបិទការស៊ើបសួរ

# ជំពូកទី៣
# ការបិទការស៊ើបសួរ

បន្ទាប់ពីចៅក្រមស៊ើបសួរបានធ្វើការស៊ើបសួរតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ឬតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ ចៅក្រមស៊ើបសួរត្រូវពិរណា ថាត្រូវបិទការស៊ើបសួរ ឬបន្តការស៊ើបសួរ ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចបិទការស៊ើបសួរចៅក្រមស៊ើបសួរធ្វើតាមនីតិវិធីនៃការបិទការស៊ើបសួរ(**៣.១.**) ។ នៅពេលដែលបំពេញនីតិវិធីក្នុងការបិទការស៊ើបសួររួចហើយចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ(**៣.២.**) ដើម្បីកំណត់អំពីពីរុទ្ធភាព ។ក្រោយពេលនៃការចេញដីកាដំណោះស្រាយរួចហើយ នោះវានឹងបង្កើតអានុភាព(**៣.៣.**) មួយចំនួនដល់បុគ្គលដែលពាក់ព័ន្ធដូចជា ជនត្រូវចោទ ម្ចាស់នៃវត្ថុតាង រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

## ៣.១.នីតិវិធីនៃការបិទការស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរបានសម្រេចបិទការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ(**៣.១.១.**) ។ បន្ទាប់ពីជូនដំណឹងរួចចៅក្រមស៊ើបសួរត្រូវមានដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា(**៣.១.២.**)ដោយមាន ឬគ្មានភ្ជាប់ជាមួយនូវការស្នើសុំបំពេញកិច្ចផ្សេងៗ។

### ៣.១.១.ការជូនដំណឹង

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូន ព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី [97] ។

នៅក្នុងដំណាក់កាលនេះ ជនត្រូវចោទ(មាត្រា១៣៣) ដើមបណ្តឹងរដ្ឋប្បវេណី(មាត្រា១៣៤) និងមេធាវីអាចស្នើសុំបំពេញកិច្ចដល់ចៅក្រមស៊ើបសួរឱ្យបំពេញកិច្ចបន្ថែម លើចំណុចណាដែលខ្លួនយល់ឃើញថាមានប្រយោជន៍។

### ៣.១.២.ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

រយៈពេល ២ (ពីរ) ថ្ងៃ ក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវអាចធ្វើការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញាបាន។ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួននិង ១ (មួយ) ខែក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសុំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានដីកាស

[97] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៤៦ កថាខណ្ឌទី១

ន្និ-ដ្ឋានស្ថាពរភ្ជាប់ជាមួយផង ។ ថិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសុំណុំរឿង ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់ នោះព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់[98] ។ ស្របពេលជាមួយគ្នានេះផងដែរ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ពុំមានអានុភាពចងចៅក្រមស៊ើបសួរឱ្យធ្វើតាមនោះទេ ពោលគឺជាចៅក្រមស៊ើបសួរជាចៅក្រមឯករាជ្យពុំមានឋានានុក្រមដូចទៅនឹងស្ថាប័នអយ្យការនោះទេ ។

## ៣.២.ដីកាដំណោះស្រាយ

ដីកាដំណោះស្រាយជាយន្តការមួយក្នុងការបិទបញ្ចប់នូវការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដោយសម្រេចថាតើបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ(**៣.២.១.**) ឬលើកលែងការចោទប្រកាន់(**៣.២.២.**)ចំពោះជនត្រូវចោទ [99]។

### ៣.២.១.ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាដីកាដំណោះស្រាយមួយប្រភេទ ដែលក្នុងនោះចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះដោយសារតែយល់ឃើញថា ជននេះពិតជាបានប្រព្រឹត្តអំពើដែលជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ[100]។ ក្នុងន័យនេះអំពើដែលបង្កើតបានជាបទល្មើសដែលត្រូវបានចៅក្រមស៊ើបសួររកឃើញនូវពិរុទ្ធភាពដែលជាបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ ចៅក្រមស៊ើបសួរត្រូវធ្វើការចេញដីកាបញ្ជូរឿងទៅជំនុំជម្រះ ដើម្បីស្នើសុំឱ្យដាក់ទណ្ឌកម្មលើជនត្រូវចោទដោយយុត្តាធិការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់[101]។

### ៣.២.២.ដីកាលើកលែងការចោទប្រកាន់

ដីកាលើកលែងការចោទប្រកាន់ជាប្រភេទមួយនៃដីកាដំណោះស្រាយ ដែលចៅក្រមស៊ើបសួរសម្រេចឱ្យជនត្រូវចោទរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ។ ក្នុងន័យនេះទោះបីជាមានការសម្រេចលើកលែងការចោទប្រកាន់ក៏ដោយប៉ុន្តែវាមិនមែនមានន័យថាការសម្រេចដោយចៅក្រមស៊ើបសួរមានអាជ្ញាអស់ជំនុំ[102] នោះទេគឺ

---

[98] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៤៦ កថាខណ្ឌទី២,៣,៤ និងកថាខណ្ឌទីចុងក្រោយ

[99] ច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា២៤៧ កថាខណ្ឌទី១

[100] សៀវភៅនីតិព្រហ្មទណ្ឌទូទៅ (សន្ទានុក្រម ពាក្យច្បាប់) សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត

[101] ច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា២៤៧ កថាខណ្ឌទី២

[102] អាជ្ញាអស់ជំនុំ សំដៅដល់ជនណាដែលតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ(មាត្រា១២នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ប្រសិនបើលេចឡើងនូវបន្ទុកថ្មីការស៊ើបសួរអាចត្រូវបើកឡើងវិញតាមគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ៖

(១).អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ។

(២).ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។

(៣).គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

(៤).ករណីដែលបណ្តឹងអាជ្ញារលត់ ។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ ចំពោះអំពើដទៃទៀត ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែង ចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថាមិនមានការពាក់ព័ន្ធ នឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុនឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជា សាធារណៈដោយមានការចូលរួមពីតំណាងអយ្យការនិងបុគ្គលពាក់ព័ន្ធប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញ សាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។ បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជា កម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រមប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធី នៃការជំនុំជម្រះរបស់តុលាការ និង

ក្នុងរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គល នេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្ដឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ[103] ។

ទន្ទឹមនឹងនេះចំពោះការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេច អំពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក ។ នៅពេលដែល វត្ថុតាង[104] ដែលបានចាប់យកនោះស្ថិតនៅក្នុងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវប្រគល់វត្ថុនោះទៅឱ្យកម្មសិទ្ធិករវិញ លើកលែងតែវត្ថុនោះ មានភាពគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬ ជាតិផ្ទុះ ព្រមទាំងវត្ថុដែលកាន់កាប់ដោយខុសច្បាប់ទើបមិនអាចប្រគល់ឱ្យកម្មសិទ្ធិករវិញ ហើយវត្ថុទាំងនេះគឺជាកម្មវត្ថុនៃការរឹបអូសទុកជាសម្បត្តិរបស់រដ្ឋ ឬត្រូវបំផ្លាញចោល។ ករណីវត្ថុដែលមិនធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ ឬអាយុជីវិតរបស់មនុស្សនោះទេ កម្មសិទ្ធិករអាចប្ដឹងទៅសភាស៊ើបសួរបាន [105] ។

## ៣.៣.អានុភាពនៃដីកាដំណោះស្រាយ

ដីកាដំណោះស្រាយនឹងបង្កើតអានុភាព នៅពេលផុតរលត់រយៈពេលនៃការប្ដឹងឧទ្ធរណ៍របស់បុគ្គលដែលអាចប្ដឹងឧទ្ធរណ៍បាន។ ដោយបុគ្គលទាំងនោះរួមមាន អគ្គព្រះរាជអាជ្ញា រយៈពេលនៃការប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ មានរយៈពេល០១ខែ គិតចាប់ពីពេលប្រកាសដីកា ដោយឡែកចំពោះព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីវិញគឺមានរយៈពេលតែ ០៥ថ្ងៃនោះទេ គិតពីថ្ងៃជូនដំណឹង[106] ។ ជាការពិតណាស់ពេលដីកាដំណោះស្រាយចូលជាស្ថាពរហើយនោះវានឹងបង្កើតអានុភាពចំនួនពីរ អានុភាពចំពោះការឃុំខ្លួនបណ្ដោះអាសន្ន (**៣.៣.១.**) និងអានុភាពចំពោះការត្រួតពិនិត្យតាមផ្លូវតុលាការ (**៣.៣.២.**)។

### ៣.៣.១.អានុភាពចំពោះការឃុំខ្លួនបណ្ដោះអាសន្ន

ដូចដែលបានបកស្រាយខាងលើរួចហើយ ប្រសិនបើចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយនោះអានុភាពនៃការឃុំខ្លួនជាបណ្ដោះអាសន្ននឹងត្រូវបញ្ចប់[107] ។ ក្នុងករណីនេះការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាពឡើងវិញគឺ ត្រូវរងចាំរហូតដល់ផុតរយៈពេលនៃការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាលើកលែង

[103] ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧ កថាខណ្ឌទី៣,៤,៥,៦,៧ និងកថាខណ្ឌទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[104] វត្ថុតាងសំដៅលើវត្ថុរូបីដែលជាភស្តុតាងនៅក្នុងកិច្ចស៊ើបអង្កេត និងកិច្ចស៊ើបសួរ។ វត្ថុតាងមានបីប្រភេទ វត្ថុដែលជាកម្មវត្ថុនៃការប្រព្រឹត្តបទល្មើស វត្ថុដែលជាផលនៃការប្រព្រឹត្តបទល្មើស វត្ថុដែលជាតួរនៃការប្រព្រឹត្តបទល្មើស។

[105] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៤៨, មាត្រា១១៩

[106] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៦៦,២៦៨

[107] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៤៩ កថាខណ្ឌទី១

តែការដោះលែងនោះមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញាត្រូវដោះលែងភ្លាម[108] ។

ប៉ុន្តែតាមសេចក្ដីសម្រេចដោយឡែកនៃដីកាដំណោះស្រាយចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទ ឱ្យនៅជាប់ឃុំបណ្ដោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ ។ នៅក្នុងដីកានេះចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌស្ដីពី មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ។ សេចក្ដីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្ដោះអាសន្ន លែងមានអានុភាពក្នុងរយៈពេល ៤ (បួន) ខែ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤ (បួន) ខែនោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង[109] ។ បានសេចក្ដីថាប្រសិនបើចៅក្រមស៊ើបសួរមានការបារម្ភថាខ្លាចជនត្រូវចោទមានការរត់គេចខ្លួន ឬមិនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការនោះចៅក្រមស៊ើបសួរអាចសម្រេចឱ្យជនត្រូវចោទឃុំខ្លួនបណ្ដោះអាសន្នតាមរយៈសេចក្ដីសម្រេចដោយឡែកនោះ។

**៣.៣.២.អានុភាពចំពោះការត្រួតពិនិត្យតាមផ្លូវតុលាការ**

ដីកាដំណោះស្រាយបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ ។ បានសេចក្ដីថានៅពេលដែលចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយហើយ នោះការត្រួតពិនិត្យតាមផ្លូវតុលាការនឹងបញ្ចប់ពេលគឺពុំមានអានុភាពអនុវត្តលើជនត្រូវចោទទៀតនោះទេ ។

